**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ដល់ថ្ងៃទី ២៣ខែឧសភា ឆ្នាំ ២០២២

ស្រាវជ្រាវដោយនិស្សិតឈ្មោះ

**កញ្ញា អ៊ឹង មួយគីម**

**លោក អ៊ុន វិទូ**

សាស្ត្រាចារ្យណែនាំ

**លោក ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ដល់ថ្ងៃទី ២៣ខែឧសភា ឆ្នាំ ២០២២

ស្រាវជ្រាវដោយនិស្សិតឈ្មោះ

**កញ្ញា អ៊ឹង មួយគីម**

**លោក អ៊ុន ឋិទ្ធ**

សាស្ត្រាចារ្យណែនាំ

**លោក ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **អ៊ីន មួយគីម** និង **អ៊ុន ទិទ្ធ** ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ ក្រុម L4A3 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសូមគោរពដឹងគុណ និងថ្លែងនូវអំណរអរគុណយ៉ាងក្រៃលែងគ្មានអ្វីមកប្រៀបប្រដូចបានដល់គុណលោកឪពុកអ្នកម្តាយទាំងទ្វេជាទីគោរពស្រលាញ់របស់កូន ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅដល់កូនៗតាំងពីកូននៅតូចរហូតដល់ពេលនេះ ប្រកបដោយព្រហ្មវិហារធម៌ទាំងបួន និងភាពកក់ក្តៅដែលមានលោកជាមាតាបិតាសម្រាប់កូន។ មិនថាក្នុងស្ថានភាពបែបណា លោកទាំងពីរមិនភ្លេចក្នុងការអប់រំទូន្មានដល់កូនៗ យកចិត្តទុកដាក់ និងតែងតែលើកទឹកចិត្តគ្រប់ពេល។ ក្រៅពីការអប់រំអំពីសីលធម៌ក្នុងការរស់នៅក្នុងសង្គម និងគ្រួសារ លោកក៏បានបញ្ជូនកូនៗទៅសាលារៀន ដើម្បីទទួលបានការអប់រំបណ្តុះបណ្តាលផ្នែកចំណេះដឹងទូទៅ ដោយមិនគិតពីការនឿយហត់ ការចំណាយចាយវាយទាំងឡាយ ទាំងពេលវេលា និងថវិកា មិនត្រឹមតែប៉ុណ្ណោះលោកតែងតែជម្រុញ និងលើកទឹកចិត្ត និងគាំទ្រយ៉ាងខ្លាំងរហូតកូនៗ ចូលរៀនថ្នាក់ឧត្តមសិក្សា។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំ បានចូលមកសិក្សានៅសាកលវិទ្យាល័យមួយនេះ និងជាពិសេសបានផ្តល់ឱកាសដល់យើងខ្ញុំបានចូលរួមក្នុងការសរសេរសារណាបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្រៃលែង ចំពោះសាស្ត្រាចារ្យ **ហ៊ាង ឡេង** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបានទទួលយល់ព្រមនៅក្នុងការដឹកនាំសារណារបស់យើងខ្ញុំទាំងពីរ ជាពិសេសលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ លើកទឹកចិត្ត និងណែនាំដល់យើងខ្ញុំឱ្យខិតខំប្រឹងប្រែងធ្វើកិច្ចការសារណានេះ ឱ្យទទួលជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមលើកហត្ថប្រណមបួងសួងសុំដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិទាំងអស់ដែលមាននៅក្នុងលោកនេះ សូមតាមជួយតាមថែរក្សា លោកឪពុកអ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាស្ត្រាចារ្យ និងមិត្តភក្តិរួមជំនាន់ទាំងអស់ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងទទួលបាននូវសុខសុភមង្គល ទទួលទានមានបានក្នុងក្រុមគ្រួសារ និងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ពេលវេលាបួនឆ្នាំជានិស្សិតផ្នែកនីតិសាស្ត្រនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបានបញ្ចប់ ថ្វីត្បិតតែពេលវេលាមួយនេះហាក់ដើរលឿនបន្តិចក៏ពិតមែន តែវាបានប្តូរមកនូវចំណេះដឹង បទពិសោធន៍ និងអនុស្សាវរីយ៍ល្អៗជាច្រើន ដែលមិនអាចបំភ្លេចបាន។ ការសិក្សាផ្នែកនីតិសាស្ត្រមិនមែនជារឿងងាយស្រួលដូចអ្វីដែលបានគិតនោះទេ ពោលយើងត្រូវសិក្សាបែបវិភាគទៅលើ ទ្រឹស្តី និងបទបញ្ញត្តិនៃច្បាប់នីមួយៗ ហើយការសិក្សាទៀតសោធន៍ទាមទារឱ្យយើងត្រូវយកចិត្តទុកដាក់ ខិតខំប្រឹងប្រែង និងអានសៀវភៅជាលក្ខណៈអត្ថបទច្បាប់ជាច្រើន ដែលជាហេតុធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងដល់និស្សិតទាំងអស់គ្នា។ ហេតុដូចនេះហើយ ដើម្បីជាការឆ្លើយតបទៅនឹងការលំបាកដែលយើងខ្ញុំធ្លាប់បានឆ្លងកាត់មក និងដើម្បីសម្រួលដល់និស្សិតជំនាន់ក្រោយ ក្នុងការស្វែងយល់បន្ថែម ទើបសារណាស្តីពី " **ចៅក្រមស៊ើបសួរ**" ដែលអ្នកកំពុងកាន់ក្នុងដៃនេះលេចរូបរាងឡើង។

ជាការពិតណាស់ ការតាក់តែងសារណាមួយនេះឡើងមក ត្រូវចំណាយកម្លាំង ការត្រិះរិះពិចារណា ការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើន និងអាននូវរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធ ដើម្បីអាចទទួលបាននូវសារណាបញ្ចប់ការសិក្សាមួយដែលត្រឹមត្រូវ និងច្បាស់លាស់។ ជារួមមក សារណាមួយនេះ គឺជាសមិទ្ធិផលថ្មីមួយរបស់យើងខ្ញុំ តាមរយៈការតាក់តែងយ៉ាងយកចិត្តទុកដាក់ ការស្រាវជ្រាវយ៉ាងប្រុងប្រយ័ត្ន និងការខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាព។ អាស្រ័យហេតុនេះ យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះនឹង អាចរួមចំណែក ក្នុងការពង្រឹង និងពង្រីកចំណេះដឹង ក៏ដូចជាផ្តល់ការស្វែងយល់បន្ថែមទៀត ដល់អ្នកសិក្សាស្រាវជ្រាវ របស់មិត្តអ្នកអាន និងនិស្សិតទាំងអស់ដែលបានអានអត្ថបទសារណាមួយនេះ។

ជាចុងបញ្ចប់ថ្វីត្បិតថា សារណាមួយនេះត្រូវបានយើងខ្ញុំតាក់តែងមកយ៉ាងយកចិត្តទុកដាក់ក៏ដោយ យើងខ្ញុំនៅតែជឿជាក់ថា កំហុសឆ្គងដោយប្រការណាមួយ ដែលអាចនឹងកើតឡើង ដោយមិនអាចជៀសផុតបានឡើយ ដែលអាចជាកំហុសផ្នែកអក្ខរាវិរុទ្ធ ការប្រើពាក្យពេជន៍ វេយ្យាករណ៍ និងការភ្ជាប់ឃ្លាល្បះក្តី ដោយការប្រើប្រាស់មិនបានត្រឹមត្រូវជាដើម ដូច្នេះយើងខ្ញុំ សូមមេត្តា អភ័យទោសទុកជាមុន។ យើងខ្ញុំនឹងរង់ចាំទទួលយកការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ សាស្ត្រាចារ្យ បញ្ញាវ័ន្ត និងបណ្តានិស្សិតទាំងអស់ ដើម្បីចូលរួមកែសម្រួល និងបំពេញបន្ថែមនូវរាល់ចំណុចខ្វះខាតដែលអាចកើតមានឡើងដោយកំហុសអចេតនា។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ**

**ផ្នែកទី១៖ គោលការណ៍នៃការស៊ើបសួរ** ........ ៦

**១.១.ការសម្ងាត់ក្នុងការស៊ើបសួរ** ........ ៦

**១.២. ឯករាជ្យភាពនៃការស៊ើបសួរ** ........ ៦

**១.៣.វិសមិតភាពមុខងារ** ........ ៧

**ផ្នែកទី២៖ ការប្តឹងទៅចៅក្រមស៊ើបសួរ** ........ ៧

**២.១ ការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់អយ្យការ** ........ ៨

**២.២ ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ** ........ ៨

**ផ្នែកទី៣៖ យុត្តាធិការស៊ើបសួរ** ........ ៩

**៣.១. រចនាសម្ព័ន្ធនៃចៅក្រមស៊ើបសួរ( មន្ទីរ និងសភាស៊ើបសួរ )** ........ ៩

**៣.២. សមត្ថកិច្ចនៃចៅក្រមស៊ើបសួរ** ........ ១០

៣.២.១. សមត្ថកិច្ចតាមកាលប្បវត្តិនៃដំណាក់កាលនីតិវិធី ........ ១០

៣.២.២. សមត្ថកិច្ចតាមដែនដី ........ ១២

**៣.៣. វិសាលភាពនៃអំណាចរបស់ចៅក្រមស៊ើបសួរ** ........ ១២

**ជំពូកទី២**

**ដំណើរការនៃការបើកការស៊ើបសួរ**

**ផ្នែកទី១៖ បែបបទនៃការស៊ើបសួរនៃចៅក្រមស៊ើបសួរ** ........ ១៤

**១.១.របៀបនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ** ........ ១៤

១.១.១. ការស៊ើបសួរដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ..... ១៤
១.១.២.ការស៊ើបសួរជំនួស ..... ១៥
១.១.២.១ ដីកាចាត់ឱ្យស៊ើបសួរជំនួស ..... ១៥
១.១.២.២ វិធានការនៃការស៊ើបសួរជំនួសរបស់មន្ត្រីនគរបាលយុត្តិធម៌ ..... ១៦
១.១.៣.ការស៊ើបសួរដោយការស្នើសុំ ..... ១៧
១.១.៣.១ ការស្នើសុំរបស់ព្រះរាជអាជ្ញា ..... ១៨
១.១.៣.២ ការស្នើសុំរបស់ជនត្រូវចោទ ..... ១៨
១.១.៣.៣ ការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..... ១៨
**ផ្នែកទី២៖ កិច្ចការរបស់ចៅក្រមស៊ើបសួរ ..... ១៩**
**២.១.ការចុះដល់ទីកន្លែងកើតហេតុ ..... ១៩**
**២.២. សួរចម្លើយជនត្រូវចោទ ..... ១៩**
២.២.១ វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ ..... ១៩
២.២.២ ការសួរចម្លើយជនត្រូវចោទ ..... ២០
២.២.៣ រយៈពេលនៃការសួរចម្លើយ ..... ២០
២.២.៤ សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ ..... ២០
**២.៣. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ..... ២០**
**២.៤. ការចុះឆែកឆេរ និងការចាប់យកវត្ថុតាង ..... ២១**
**២.៥. ការស្តាប់ចម្លើយសាក្សី ..... ២២**
**ផ្នែកទី៣៖ វិធានការនិរន្តរាយ ..... ២៣**
**៣.១ ដីកាបង្គាប់ឱ្យចូលខ្លួន ..... ២៣**
**៣.២ ដីកាបង្គាប់ឱ្យនាំខ្លួន ..... ២៤**
**៣.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន ..... ២៥**

**៣.៤ ដីកាបង្គាប់ឱ្យឃុំខ្លួន** ........ ២៧
**ផ្នែកទី៤៖ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ** ........ ២៧
**៤.១. ដីកាបង្គាប់ដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ** ........ ២៩
**៤.២ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ** ........ ២៩
៤.២.១ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ ........ ២៩
៤.២.២ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា ........ ៣០
៤.២.៣ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ ........ ៣០
**៤.៣ ការគេចវេះពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ** ........ ៣១
**៤.៤. ការកោះហៅ និងការជូនដំណឹង** ........ ៣២
៤.៤.១ រយៈពេលរួម ........ ៣២
៤.៤.២ របៀបនៃការកោះហៅ ........ ៣២
៤.៤.៣ ការជូនដំណឹង ........ ៣២
៤.៤.៤ ការប្រគល់ដីកាកោះហៅ ឬដីកាផ្សេងៗទៀត ........ ៣៣
**ផ្នែកទី៥៖ ការឃុំខ្លួនបណ្តោះអាសន្ន** ........ ៣៤
**៥.១.មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន** ........ ៣៤
**៥.២.កំណត់សម្គាល់របស់ជនត្រូវចោទ** ........ ៣៥
**៥.៣.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន** ........ ៣៦
៥.៣.១ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន ........ ៣៦
៥.៣.២ ថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ........ ៣៧
**៥.៤.ការដោះលែងឱ្យនៅក្រៅឃុំ** ........ ៣៨
**៥.៥.តាមបណ្តឹងរបស់ព្រះរាជអាជ្ញា និងជនត្រូវចោទ** ........ ៣៨
**៥.៦.ការជូនដំណឹងអំពីការដោះលែងឱ្យនៅក្រៅឃុំ** ........ ៣៩

## ជំពូកទី៣

## ការបិទការស៊ើបសួរ


**ផ្នែកទី១. នីតិវិធីនៃការបិទការស៊ើបសួរ** ........ ៤០

**១.១. ការជូនព័ត៌មានដោយចៅក្រមស៊ើបសួរ** ........ ៤០

១.១.១ ការជូនដំណឹងដល់គូភាគី ........ ៤០

១.១.២ ការស្នើសុំបំពេញកិច្ចបន្ថែម ........ ៤១

**១.២. ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា** ........ ៤១

**ផ្នែកទី២. ប្រភេទនៃដីកាដំណោះស្រាយ** ........ ៤២

**២.១. ដីកាលើកលែងការចោទប្រកាន់** ........ ៤៣

**២.២. ការបើកការស៊ើបសួរលើបន្ទុកថ្មី** ........ ៤៤

**សេចក្តីសន្និដ្ឋាន** ........ ៤៥

**អនុសាសន៍** ........ ៤៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងក្របខណ្ឌនៃការចូលរួមអនុវត្តគោលនយោបាយកំណែប្រព័ន្ធទម្រង់ច្បាប់ និងយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជាយើង ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដើម្បីបំពេញតម្រូវការនៃសង្គមកម្ពុជាដែលចង់បានក្រមនីតិវិធីព្រហ្មទណ្ឌមួយយ៉ាងពេញលេញ និងច្បាស់លាស់ ក្រសួងយុត្តិធម៌បានបង្កើតក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឡើង ក្នុងរយៈពេលជាង១០ឆ្នាំ។ យើងឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌជាឧបករណ៍ដ៏សំខាន់សម្រាប់ មធ្យោបាយរបស់តុលាការផ្នែកព្រហ្មទណ្ឌ ហើយក៏ជាអត្ថបទមូលដ្ឋានសម្រាប់ការកសាងនីតិរដ្ឋនៅកម្ពុជា។

ការរៀបចំក្រមនេះឡើង គឺគោរពនូវគោលការណ៍ដែលច្បាប់យើងមានស្រាប់(ច្បាប់នីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៩៣) ដោយគោលការណ៍នេះបានធានានូវនិរន្តភាពនៃស្ថាប័ន ប្រពៃណីច្បាប់នៅកម្ពុជាដែលយើងឃើញថា ក្នុងក្រមខណ្ឌនៃព្រហ្មទណ្ឌ បានរក្សាទុកនូវស្ថាប័នមួយគឺ **ចៅក្រមស៊ើបសួរ** និងបានបង្កើននិងផ្តល់នូវតួនាទីចម្បងដល់ចៅក្រមស៊ើបសួរ នៅក្នុងដំណាក់កាលនៃការស្វែងរកភស្តុតាង និងការស្វែងរកបទល្មើស។ គោលការណ៍ដែលក្រមនីតិវិធីព្រហ្មទណ្ឌថ្មី បានគោរពនូវសិទ្ធិការពារខ្លួនជនជាប់ចោទ និងលើកតម្កើននូវសិទ្ធិរបស់ជនរងគ្រោះ ហេតុនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌយើងបានកំណត់នូវប្រព័ន្ធមួយគឺ **ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** ហើយចំណុចថ្មីមួយទៀត គឺបានបង្កើតយុត្តាធិការស៊ើបសួរជាពីរថ្នាក់ ដើម្បីធានាប្រសិទ្ធិភាពនៃការស៊ើបសួរស្វែងរកភស្តុតាង។

រឿងក្តីព្រហ្មទណ្ឌគឺជាប្រតិកម្មតាមផ្លូវតុលាការរបស់សង្គម នៅពេលដែលមានការរំលោភច្បាប់ ឬវិធានដែលគ្រប់គ្រងសង្គម សង្គមនឹងមានប្រតិកម្មតប ដែលនិយាយបានថា ចាប់ពីពេលដែលបទល្មើសមួយត្រូវបានប្រព្រឹត្ត រហូតដល់ការដាក់ទណ្ឌកម្មមាននីតិវិធីមួយត្រូវបានដំណើរការហៅថា រឿងក្តីព្រហ្មទណ្ឌ។ ហើយវិធានទាក់ទងដល់ការរៀបចំ ប្រព្រឹត្តទៅ និងការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌនេះ បង្កើតបានជាសំណុំនៃវិធានមួយហៅថា នីតិវិធីព្រហ្មទណ្ឌ។

នីតិវិធីព្រហ្មទណ្ឌបានកំណត់អំពី នីតិវិធីនៃការពិនិត្យ ការចោទប្រកាន់បទល្មើស ការស្រាវជ្រាវរកជនល្មើស ការស្វែងរកភស្តុតាង ព្រមទាំងនីតិវិធីនៃការជំនុំជម្រះ។ ដោយគិតថាលំដាប់លំដោយនៃពេលវេលាដំណើរការនៃរឿងក្តីព្រហ្មទណ្ឌមាន៤គឺ៖ ដំណាក់កាលនៃការស៊ើបអង្កេតដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា ដំណាក់កាលនៃការចោទប្រកាន់ដែលអនុវត្តដោយព្រះរាជអាជ្ញាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដោយកំណត់ថា មានតែអង្គអយ្យការទេ ដែលមានសិទ្ធិធ្វើ

បណ្តឹងអាជ្ញា[1] ហើយដំណាក់កាលបន្ទាប់គឺ ដំណាក់កាលនៃការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ ហើយ និងដំណាក់កាលនៃការជំនុំជម្រះធ្វើឡើងដោយយុត្តាធិការជំនុំជម្រះ។

ដោយមើលឃើញពីកំណែទម្រង់លើវិស័យយុត្តិធម៌បែបនេះហើយ និងមានការចាប់អារម្មណ៍ចង់បង្កើន នូវចំណេះដឹង និងចែករំលែកទៅលើដំណើរការនៃរឿងក្តីព្រហ្មទណ្ឌនេះហើយ ទើបយើងខ្ញុំដែលជានិស្សិត បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ បានខិតខំធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងនូវសៀវភៅសារណានេះឡើង ដោយ បានលើកយកនូវបទបញ្ញត្តិពិសេសៗ និងចំណុចសំខាន់អំពីចៅក្រមស៊ើបសួរ ដើម្បីជាប្រទីបសម្រាប់បំភ្លឺដល់ មិត្តនិស្សិតអ្នកអាន ឬសាធារណជនអាចយកទៅសិក្សាស្វែងយល់ ដើម្បីទទួលបាននូវចំណេះដឹងនូវចំណុច សំខាន់ៗនៃប្រធានបទនេះឱ្យកាន់តែច្បាស់ និងកាន់តែស៊ីជម្រៅ។

## ២. ចំណោទបញ្ហា

ដោយហេតុថា ការសិក្សាជុំវិញបរិបទនៅការស៊ើបសួររបស់ចៅក្រមស៊ើបសួរ បានលេញចេញឡើងនូវ វិធានច្បាប់ជាច្រើនដែលមានលក្ខណៈស្មុគស្មាញ ប្រទាក់ក្រឡា និងទូលំទូលាយ យើងខ្ញុំជានិស្សិតបាន សម្រេចចិត្តធ្វើការកំណត់នូវសំណួរស្រាវជ្រាវមួយចំនួនឡើងមក ដើម្បីតម្រង់ទិសដៅសម្រាប់សារណាមួយនេះ ដែលមានដូចខាងក្រោម៖

១. តើអំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. តើក្នុងក្របខណ្ឌនៃវិធានការនិរន្តរាយ ផ្តល់អំណាចអ្វីខ្លះដល់ចៅក្រមស៊ើបសួរ?

៣. តើចៅក្រមស៊ើបសួរបិទការស៊ើបសួរយ៉ាងដូចម្តេច?

ចំពោះចម្លើយនៃសំណួរស្រាវជ្រាវដែលបានចោទនេះនឹង ត្រូវបង្ហាញក្នុងរូបភាពជាសៀវភៅសារណា ដែលមានចំណងជើងថា " **ចៅក្រមស៊ើបសួរ**" យ៉ាងក្បោះក្បាយទាំងស្រុងតែម្តង។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទណាមួយ សុទ្ធសឹងតែមានគោលបំណងចង់បង្ហាញ និង ដោះស្រាយនូវបញ្ហាណាមួយដែលជាចម្ងល់របស់ការសិក្សាស្រាវជ្រាវ។ មិនខុសអ្វីពីការលើកឡើងខាងលើ ប្រធានបទនេះ គឺយើងខ្ញុំជានិស្សិតបានកំណត់នូវគោលបំណងរួចជាស្រេច ដែលមានដូចតទៅ៖

- ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ ពីការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ជាពិសេស ដំណើរការនីតិវិធីក្នុង ការអនុវត្តអំណាចរបស់ចៅក្រមស៊ើបសួរ។

[1]មាត្រា ១៣១ ថ្មី(មាត្រា១១២ ចាស់) រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

- ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពី អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការឃុំខ្លួនជនត្រូវចោទ និងការអនុវត្តនីតិវិធីក្នុងការឃុំខ្លួន។
- ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពី វិធានការនិរន្តរាយ របស់ចៅក្រមស៊ើបសួរ។
- ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពី ការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ តាមរយៈដីកាដំណោះស្រាយ។
- ចងក្រងទុកឯកសារ សម្រាប់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជានិស្សិត ឱ្យមានការយល់ដឹងបន្ថែមពីអំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងរឿងព្រហ្មទណ្ឌ។
- ចងក្រងទុកជា ឯកសារ និងស្នាដៃសម្រាប់យើងខ្ញុំផ្ទាល់។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណានេះ យើងខ្ញុំបានកំណត់នូវទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ គឺដោយចាប់ផ្តើមពី ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ រហូតដល់ការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរតាមរយៈដីកាដំណោះស្រាយ។ ដោយយើងមិនបានធ្វើការពង្រីកវិសាលភាពទៅដល់សភាស៊ើបសួរនូវវិធាន និងនីតិវិធីនានាឱ្យមានលក្ខណៈក្បោះក្បាយបាននោះទេ ដោយសារតែពេលវេលាមានកំណត់។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងអាចដោះស្រាយ និងបកស្រាយនូវចម្ងល់មួយផ្នែករបស់អ្នកសិក្សាស្រាវជ្រាវ និងនិស្សិតទាំងអស់ ដែលធ្លាប់មានចម្ងល់ទាក់ទងនឹងប្រធានបទមួយនេះ។ លើសពីនេះទៅទៀត តាមរយៈសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំអាចមានឱកាសទាញយកចំណេះដឹងយ៉ាងច្រើនសន្ធឹកសន្ធាប់ ពីការស្រាវជ្រាវលើប្រធានបទមួយនេះផងដែរ។ ជាការពិតណាស់ ថ្វីត្បិតតែសារណាបញ្ចប់ការសិក្សាមួយនេះ គ្រាន់តែជាសមិទ្ធិផលដ៏ដូចមួយរបស់យើងខ្ញុំ ប៉ុន្តែយើងខ្ញុំជឿជាក់ថា វានឹងផ្តល់ជាបទពិសោធន៍ដ៏ល្អមួយក្នុងការអភិវឌ្ឍចំណេះដឹង និងការស្វែងយល់បន្ថែម របស់យើងខ្ញុំផ្ទាល់ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ និងនិស្សិតទាំងអស់ដែលបានអានអត្ថបទសារណាមួយនេះ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ យើងខ្ញុំបានប្រើប្រាស់នូវវិធីសាស្ត្រជាច្រើនដើម្បីជាជំនួយក្នុងការសរសេរចងក្រងសៀវភៅសារណានេះឡើង ដែលមានដូចជា៖

## ក. វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យជាឯកសារ

មុនការចាប់ផ្តើមរៀបរៀងឯកសារ យើងខ្ញុំបានរិះរកប្រមូលទិន្នន័យដែលនឹងជាស្ពានជំនួយក្នុងសរសេរសារណាជាមុនសិន ដែលទិន្នន័យដែលរកបានទាំងនោះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញឱ្យដំណើរការក្នុងការរៀបរៀងសៀវភៅសារណានេះបានជោគជ័យ។

ប្រភពនៃទិន្នន័យជាឯកសារ ដែលយើងបានប្រមូលបានរួមមាន៖

- អត្ថបទច្បាប់ដែលមានជាធរមាន (រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ.......)
- លិខិតបទដ្ឋានគតិយុត្តិ បទប្បញ្ញត្តិនានាដែលត្រូវបានប្រកាស
- ការជួបសម្ភាសន៍ សន្ទនាផ្លាស់ប្តូរគំនិតផ្ទាល់ជាមួយសាស្ត្រចារ្យដឹកនាំ ឬបុគ្គលដែលមានបទពិសោធន៍ផ្សេងទៀត
- កម្រងមេរៀនដែលចងក្រងដោយសាស្ត្រចារ្យ
- កម្រងអត្ថបទស្រាវជ្រាវវែង ខ្លី ដែលចងក្រងដោយរៀមច្បងជាអ្នកវិជ្ជាជីវច្បាប់
- ការស្រាវជ្រាវសារណាបញ្ចប់ការសិក្សា របស់រាមច្បងដែលបានធ្វើពីមុនមក ដើម្បីសិក្សាអំពីលំនាំ និងគម្រូ
- តំណភ្ជាប់(Links) ទៅកាន់ឯកសារ និងអត្ថបទក្នុងវិស័យច្បាប់ជាច្រើនទៀត។

## ខ. វិធីសាស្ត្រក្នុងការចងក្រង បញ្ចូលទិន្នន័យ

ចំពោះវិធីសាស្ត្រក្នុងការចងក្រងវិញគឺ យើងខ្ញុំចាប់ផ្តើមដំបូងដោយការប្រមូលឯកសារនានាជាច្រើនដែលមានលំនាំ និងព័ត៌មានពាក់ព័ន្ធ នឹងប្រធានបទឱ្យបានច្រើនទៅតាមលទ្ធភាពដែលអាចធ្វើបាន បន្ទាប់មកយើងខ្ញុំបានធ្វើការអាន វិភាគ និងកត់សម្គាល់នូវរាល់ឯកសារដែលបានប្រមូលមកទាំងអស់ បន្ទាប់មកយើងបានពិភាក្សាគ្នាជាមួយដៃគូដើម្បីបង្កើតនូវមាតិកាគម្រូមួយ ដើម្បីដឹកនាំការតាក់តែងអត្ថបទដែលជាខ្លឹមសារដោយឆ្លងកាត់ការផ្តល់យោបល់ពីសាស្ត្រចារ្យណែនាំ។ បន្ទាប់ពីមានមាតិកាហើយ ពួកយើងចាប់ផ្តើមបំពេញខ្លឹមសារនៅក្នុងសេចក្តីព្រាងដោយឡែកមួយ។ ក្រោយបញ្ចប់ការសរសេរអត្ថបទដាច់តាមផ្នែកនីមួយៗ យើងខ្ញុំតែងតែត្រួតពិនិត្យ និងកែសម្រួលទៅលើអត្ថន័យ ឃ្លោងឃ្លា និងការប្រើប្រាស់ពាក្យពេចន៍ និងជាពិសេសត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើផ្នែកអក្ខរាវិរុទ្ធ។ លុះការចងក្រងគ្រប់ផ្នែកត្រូវបានបញ្ចប់ យើងខ្ញុំក៏យកទៅធ្វើការកែសម្រួលទៅលើរចនាបទ និងទម្រង់នានាតាមដែលសាកលវិទ្យាល័យបានតម្រូវ។

## ៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **"ចៅក្រមស៊ើបសួរ"** គឺយើងបានធ្វើការបែងចែករចនាសម្ព័ន្ធជា ៣ជំពូកធំៗដែលមានដូចខាងក្រោម៖

- **ជំពូកទី១ សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ៖** ជំពូកដំបូងជាជំពូក ដែលយើងធ្វើការរៀបរាប់ជាទូទៅអំពីគោលការណ៍នៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ការប្ដឹងទៅចៅក្រមស៊ើបសួរ និងយុត្តាធិការស៊ើបសួរ ដែលមានពិពណ៌នាពី ការរៀបចំរចនាសម្ព័ន្ធរបស់យុត្តាធិការស៊ើបសួរទាំងពីរថ្នាក់ និងសមត្ថកិច្ចនៃការស៊ើបសួរផងដែរ។
- **ជំពូកទី២ ដំណើរការនៃការបើកការស៊ើបសួរ៖** នៅក្នុងជំពូកនេះ យើងធ្វើការបរិមាណធិប្បាយទៅលើចំណុចសំខាន់ៗដូចជា បែបបទនៃការបើកការស៊ើបសួរ កិច្ចការរបស់ចៅក្រមស៊ើបសួរ វិធានការនិរន្តរាយ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ និងចំណុចសំខាន់ចុងក្រោយស្តីពីការឃុំខ្លួនបណ្ដោះអាសន្ន។
- **ជំពូកទី៣ ការបិទការស៊ើបសួរ៖** នៅក្នុងជំពូកចុងក្រោយនេះ យើងបានធ្វើការពិពណ៌នាដោយបង្ហាញអំពីនីតិវិធីនៃការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងប្រភេទនៃដីកាដំណោះស្រាយ។

# ជំពូកទី១

# សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ

# ជំពូកទី១

# សញ្ញាណទូទៅរបស់ចៅក្រមស៊ើបសួរ

ប្រទេសកម្ពុជាបានរក្សានូវស្ថាប័នយុត្តាធិការស៊ើបសួរ ដើម្បីពង្រឹងនិងស្វែងរកភាពយុត្តិធម៌ ដោយយើងឃើញថា ចៅក្រមស៊ើបសួរមានភារកិច្ចស្វែងរកភស្តុតាងទាំងដោះបន្ទុក និងដាក់បន្ទុក ដើម្បីធានាការស្វែងរកយុត្តិធម៌ឱ្យកាន់តែមានភាពសុក្រឹតមានន័យថា បើសិនជាព្រះរាជអាជ្ញាជាអ្នកចោទប្រកាន់ ហើយគាត់បើកការស៊ើបសួរទៀត នោះគាត់ប្រាកដជាស៊ើបសួរស្វែងរកតែភស្តុតាងដាក់បន្ទុកតែប៉ុណ្ណោះ។ ប្រទេសមួយចំនួនមិនមានចៅក្រមស៊ើបសួរទេ ដោយការស្វែងរកភស្តុតាងជាភារកិច្ចរបស់មេធាវី ដូច្នេះប្រសិនបើបុគ្គលនោះ មិនមានប្រាក់ជួលមេធាវីល្អទេ នោះលទ្ធភាព ឬសំណាងក្នុងការឈ្នះក្តីមានតិចណាស់។

## ផ្នែកទី១៖ គោលការណ៍នៃការស៊ើបសួរ

នៅដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរដោយស្របទៅតាមគោលការណ៍ដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ១.១.ការសម្ងាត់ក្នុងការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយដែលចូលរួមក្នុងការជ្រើសរើស ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចចែងក្នុងមាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។ ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។ ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន [2]។

### ១.២. ឯករាជ្យភាពនៃការស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវតែទទួលបាននូវឯករាជ្យភាពយ៉ាងពេញលេញក្នុងការស៊ើបសួរ ដោយឯករាជ្យនោះត្រូវតែបង្ហាញអំពីសិទ្ធិក្នុងការសម្រេចថាធ្វើ ឬមិនធ្វើអ្វីមួយដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌដែលទទួលបន្ទុកស៊ើបសួរ ស្របទៅតាមឆន្ទានុសិទ្ធិ និងសម្បជញ្ញៈរបស់ចៅក្រម ។ មួយវិញទៀត ចៅក្រមស៊ើបសួរមានឯករាជ្យភាពក្នុងការស្រាវជ្រាវទៅលើសំណុំរឿងព្រហ្មទណ្ឌដែលខ្លួនទទួលបន្ទុក ធ្វើយ៉ាងណាលាតត្រដាងនូវការពិតនៃសំណុំរឿង តាមរយៈការស៊ើបអង្កេតទៅលើភស្តុតាងដែលមានស្រាប់ ក៏ដូចជាតម្រុយនានាដែល

[2] មាត្រា ១២១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

អាចចាត់ឱ្យអ្នកជំនាញដែលសមត្ថកិច្ចធ្វើការស្រាវជ្រាវបន្ថែម ដោយមិនទទួលរងនូវសម្ពាធពីភាគីណាមួយនៅក្នុងសំណុំរឿងនោះឡើយ ។

### ១.៣.វិសមិតភាពមុខងារ

វិសមិតភាព សំដៅទៅលើភាពដែលមិនអាចមាន ឬមិនអាចធ្វើការចូលគ្នាបាន អលទ្ធភាពតាមគន្លងច្បាប់ដែល មិនអាចឱ្យមនុស្សម្នាក់បំពេញមុខងារពីរកន្លែងបាន ។ រវាងមុខងារជាចៅក្រម ជាមួយនិងមុខងារជាព្រះរាជអាជ្ញា ឬជាព្រះរាជអាជ្ញារងនោះ គឺមានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត ។ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ [3]។ ចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ [4]។

នៅក្នុងរឿងក្តីព្រហ្មទណ្ឌមួយ ប្រសិនបើព្រះរាជអាជ្ញាមួយរូបបានធ្វើការចោទប្រកាន់នៅក្នុងរឿងក្តីនោះហើយ បន្ទាប់មកព្រះរាជអាជ្ញារូបនោះត្រូវបានតែងតាំងជាចៅក្រមវិញ ដូច្នេះគាត់មិនអាចក្លាយទៅជាចៅក្រមស៊ើបសួរក្នុងសំណុំរឿងដែលគាត់ធ្លាប់បានចោទប្រកាន់នោះទេ ។ ដូចគ្នាដែរ ប្រសិនចៅក្រមស៊ើបសួរដែលធ្លាប់ទទួលបន្ទុកក្នុងការស៊ើបសួរលើសំណុំរឿងមួយ គាត់ក៏មិនអាចក្លាយទៅជាចៅក្រមជំនុំជម្រះនៃសំណុំរឿងដែលគាត់ធ្លាប់ស៊ើបសួរនោះដែរ ។ ប្រសិនបើមានករណីបែបនេះណាមួយកើតឡើង នោះសាលក្រមនៃសំណុំរឿងនេះនឹងត្រូវទុកជាមោឃៈ ។

## ផ្នែកទី២៖ ការប្តឹងទៅចៅក្រមស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន[5]។

ដំណាក់កាលនៃការស៊ើបសួរ អាចកើតឡើងលុះត្រាតែមានបណ្តឹង ដែលបណ្តឹងនោះអាចជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់ព្រះរាជអាជ្ញា ឬបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

[3] មាត្រា ២៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[4] មាត្រា ៥ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, ២០១៤

[5] មាត្រា ១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

### ២.១ ការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់អយ្យការ

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដំណាក់កាលស៊ើបសួរគឺជាដំណាក់កាលបន្ទាប់ពីដំណាក់កាលចោទប្រកាន់ដោយតំណាងអយ្យការ ។ តំណាងអយ្យការ គឺជាបុគ្គលដែលតំណាងឱ្យអង្គការអយ្យការ ដោយក្នុងនោះរួមមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានី-ខេត្ត ។

ការស៊ើបសួរត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមានៈ

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះជាបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវធ្វើការចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព តែពុំដូច្នេះទេ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ[6]។

### ២.២ ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ

ចៅក្រមស៊ើបសួរ អាចទទួលពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[7] ដែលធ្វើឡើយដោយជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ។

ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវ ការដាក់ពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា។ ចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះអាចធ្វើប្រឆាំងទៅនឹងអញ្ញាតជន បើទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ [8]។

[6] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[7] មាត្រា ១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[8] មាត្រា ១៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ព្រះរាជអាជ្ញាអាចសុំកុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយផ្អែកទៅលើការរលត់បណ្ដឹងអាជ្ញា ឬដោយសារអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនធ្វើការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមួយដោយមានសំអាងហេតុ ព្រមទាំងធ្វើការជូនដំណឹងទៅដើមបណ្ដឹងរដ្ឋប្បវេណី ។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចធ្វើការស៊ើបសួរ ដូច្នេះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដើម្បីធ្វើការជូនដំណឹងដល់ព្រះរាជអាជ្ញាជាបន្ទាន់ ។

ដើម្បីការពារកុំឱ្យមានការប្ដឹងដោយបំពាន ឬអូសបន្លាយពេលវេលា ចៅក្រមស៊ើបសួរអាចធ្វើការកំណត់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុក។ ការបង់ប្រាក់តម្កល់ទុក គឺធ្វើឡើងដោយផ្អែកទៅលើធនធាននៃ ដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង[9]។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពក្នុងការបង់នូវប្រាក់តម្កល់ដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរអាចធ្វើការលើកលែង ចំពោះការបង់ប្រាក់តម្កល់នេះបាន ។ ប្រាក់តម្កល់នឹងត្រូវបានបង្វិលទៅដើមបណ្ដឹងរដ្ឋប្បវេណីវិញនៅពេលដែលនីតិវិធីត្រូវបានបញ្ចប់ ។ ផ្ទុយទៅវិញ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានីតិវិធីធ្វើឡើងដោយបំពាន ឬដោយអូសបន្លាយពេលវេលា នោះចៅក្រមស៊ើប-សួរ អាចសម្រេចតាមដីកាសម្រេចឱ្យដើមបណ្ដឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី ។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះត្រូវឱ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់ ។[10]

## ផ្នែកទី៣៖ យុត្តាធិការស៊ើបសួរ

### ៣.១. រចនាសម្ព័ន្ធនៃចៅក្រមស៊ើបសួរ( មន្ទីរ និងសភាស៊ើបសួរ)

មន្ទីស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួរលើរឿងក្ដីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ។ ដោយប្រធានសាលានៃដំបូងទាំងអស់ មានភារកិច្ចត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២(ពីរ)រូប ដែលធ្វើឡើងតាមរយៈដីកាសម្រេចឱ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅតាមមន្ទីស៊ើបសួរនៃតុលាការព្រហ្មទណ្ឌ។ យើងឃើញថាដីកាសម្រេចនេះត្រូវធ្វើការកំណត់ផងដែរអំពីលំដាប់នៃលេខរៀងសម្រេចការទទួលការបំពេញការងាររបស់ចៅក្រមស៊ើបសួរ។ ក្នុងករណីដែលមិនមានសមាសភាពចៅក្រមស៊ើបសួរ ឬមានការខ្វះខាតចៅក្រមស៊ើបសួរ ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេងទៀត ដើម្បីមកបំពេញមុខងារស៊ើបសួរបាន។[11]

---

[9] មាត្រា ១៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[10] មាត្រា ១៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[11] មាត្រា ២០ ច្បាប់រៀបចំអង្គការតុលាការ, ២០១៤

នៅសាលាឧទ្ធរណ៍មានសភាពិសេសមួយ គឺសភាស៊ើបសួរ។ សភាស៊ើបសួរមានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀតដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពី នីតិវិធីព្រហ្មទណ្ឌជាធរមាន។ សេចក្តីសម្រេចរបស់សភាស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រម០៣រូប ដែលមួយរូបជាប្រធាន។ សភាស៊ើបសួរមានតួនាទីសំខាន់ៗចំនួន៣គឺ តួនាទីផ្នែករដ្ឋបាល តួនាទីពិនិត្យមោឃភាពនៃកិច្ចនីតិវិធី និងពិនិត្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។

តួនាទីផ្នែករដ្ឋបាល៖ សភាស៊ើបសួរមានតួនាទីធានាការប្រព្រឹត្តទៅនៃមន្ទីរស៊ើបសួរតាមខេត្តក្រុងក្រោមវិសាលភាពរបស់ខ្លួនឱ្យដំណើរការបានល្អ ចៀសវាងការពន្យាពេលនីតិវិធីដោយឥតហេតុផល ដោយប្រធាននៃសភាស៊ើបសួរធ្វើអធិការកិច្ចទៅមន្ទីរស៊ើបសួររបស់ខ្លួនគ្រប់ខេត្តក្រុង ហើយត្រូវតែធ្វើរបាយការណ៍ផ្ញើទៅប្រធានសាលាឧទ្ធរណ៍។ ចៅក្រមស៊ើបសួរគ្រប់រូបនៅពេលដំណាច់ត្រីមាសនីមួយៗ ត្រូវធ្វើតារាងរាយនាមឈ្មោះរឿងទាំងអស់ដោយមានចុះនិទ្ទេស ស្តីអំពីកិច្ចចុងក្រោយនៃការស៊ើបសួរដែលខ្លួនបានបំពេញ។[12]

តួនាទីពិនិត្យមោឃភាពនៃកិច្ចនីតិវិធី៖ ដើម្បីធានាឱ្យមានប្រសិទ្ធភាព ចៀសវៀងការរំលោភសិទ្ធិរបស់ជនពាក់ព័ន្ធ ពីសំណាក់មន្រ្តីនគរបាលយុត្តិធម៌ក្នុងដំណាក់កាលស៊ើបអង្កេត ឬចៅក្រមស៊ើបសួរជាដើម។ កាលណា ពិនិត្យឃើញមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។ ជាក់ស្តែងនៅពេលទទួលបណ្តឹងសុំមោឃកម្មចំពោះកិច្ច ឬលិខិតណាមួយនៃនីតិវិធី ប្រសិនបើចៅក្រមស៊ើបសួរយល់ព្រមតាមពាក្យបណ្តឹងសុំនេះ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរឬទេ ហើយកិច្ច ឬលិខិតដែលត្រូវចាត់ទុកថាជាមោឃៈត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។[13]

ពិនិត្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ៖ បណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។[14]

## ៣.២. សមត្ថកិច្ចនៃចៅក្រមស៊ើបសួរ

### ៣.២.១. សមត្ថកិច្ចតាមកាលប្រវត្តិនៃដំណាក់កាលនីតិវិធី

ព្រំដែនតាមកាលប្រវត្តិនៃដំណាក់កាលនីតិវិធី កំណត់អំពីថា តើកិច្ចនៃការស៊ើបសួរត្រូវបានចាប់ផ្តើមនៅពេលណា ហើយនិងត្រូវបញ្ចប់នៅពេលណា? យោងតាមប្បញ្ញត្តិនៃមាត្រា៤៤នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃ

[12] មាត្រា ២៨៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[13] មាត្រា ២៨០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[14] មាត្រា ២៧១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ព្រះរាជាណាចក្រកម្ពុជា ដោយបានកំណត់ថា ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទោចៅក្រមស៊ើបសួរ។ ដូចនេះមានន័យថា ដោយគិតតាមដំណាក់កាលនៃនីតិវិធី ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួររបស់ខ្លួនបាន នៅពេលដែលទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា។ មួយវិញទៀតយើងឃើញថា ក្រៅពីការបើកការស៊ើបសួរ ដោយដីកាបញ្ជូនរឿងឱ្យស៊ើបសួរ កិច្ចនីតិវិធីនៃការស៊ើបសួរក៏អាចចាប់ផ្តើមឡើងតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែរ។ យោងតាមប្បញ្ញត្តិនៃមាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះបានកំណត់ថា ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា។ ដោយនីតិវិធីនេះ ច្បាប់កំណត់ឱ្យចៅក្រមស៊ើបសួរធ្វើការបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាក្រោយពីបានឃើញ នូវពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋ-ប្បវេណីហើយ ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូចទៅនឹងដំណើរការនៃនីតិវិធីទូទៅ។ ប្រសិនបើព្រះរាជអាជ្ញាយល់ថា បណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរបាន។ បន្ទាប់ពីនេះ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនោះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែប្រសិនបើ ចៅក្រមស៊ើបសួរនៅតែសម្រេចថាស៊ើបសួរ ចៅក្រមរូបនោះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅដល់ព្រះរាជអាជ្ញា។[15] ហើយការបើកការស៊ើបសួរតាមរយៈ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះផងដែរ ច្បាប់តម្រូវឱ្យធ្វើការបង់តម្កល់ទុក ដោយផ្អែកលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើកការលំបាកនៃនីតិវិធីដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ និងរយៈពេលដែលត្រូវបង់នោះផងដែរ។[16]

កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះ អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់នៅពេលវេលា។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍នេះ គឺធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាឡើយ ហើយកាលណាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងតាមរយៈលិខិត លិខិតនេះត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ម្យ៉ាងវិញទៀត កាលណាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ចៅក្រមស៊ើបសួរត្រូវធ្វើ

[15] មាត្រា ១៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[16] មាត្រា ១៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

កំណត់ហេតុ លើការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ ដោយនៅក្នុងក្របខណ្ឌនៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹង អំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។[17]

ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់មកដែរថា ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយពាក្យប្ដឹងនោះអាចដាក់ក្នុងនាមជនរងគ្រោះ ដោយមេធាវី។[18]

### ៣.២.២. សមត្ថកិច្ចតាមដែនដី

ចៅក្រមស៊ើបសួរស្ថិតនៅជាមួយសាលាដំបូង ដូច្នេះ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងអំពីសមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរបានកំណត់ថា៖ ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចគឺ៖ (១) ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស (២) ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស (៣) ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្ដឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល ដោយការសម្រេចនេះជា សេចក្ដីសម្រេចបិទផ្លូវតវ៉ា។

## ៣.៣. វិសាលភាពនៃអំណាចរបស់ចៅក្រមស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ ក្នុងការស៊ើបសួរនេះ វិសាលភាពនៃអំណាចរបស់ចៅក្រមស៊ើបសួរ ត្រូវបានកំណត់ព្រំដែននៃកិច្ចនីតិវិធីត្រឹមអង្គហេតុដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ តាមប្បញ្ញត្តិនៃមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយបានកំណត់ថា ចៅក្រមស៊ើបសួរទទួលបណ្ដឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវតែស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។ ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្ដឹងសុំ

[17] មាត្រា ១៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[18] មាត្រា ១៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។

# ជំពូកទី២
# ដំណើរការនៃការបើកការស៊ើបសួរ

# ជំពូកទី២

# ដំណើរការនៃការបើកការស៊ើបសួរ

## ផ្នែកទី១៖ បែបបទនៃការស៊ើបសួរនៃចៅក្រមស៊ើបសួរ

### ១.១.របៀបនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

#### ១.១.១. ការស៊ើបសួរដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ

បន្ទាប់ពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាមក ចៅក្រមស៊ើបសួរគាត់អាចបំពេញកិច្ចស៊ើបសួរទាំងអស់ដែលគាត់យល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញពីការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក។[19] នៅក្នុងកិច្ចនៃការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច ហើយទោះក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។[20] សំណុំរឿងស៊ើបសួរ ត្រូវបានរក្សាទុកដោយក្រឡាបញ្ជី ហើយក្រឡាបញ្ជីចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន ដោយលិខិតចម្លងនោះត្រូវតែបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើមដោយក្រឡាបញ្ជី ហើយសេចក្តីចម្លងនោះត្រូវរៀបចំទុកក្នុងសំណុំរឿងបង្ការទុក។ គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ។ សំណុំរឿង និងសំណុំលិខិតដែលបង្ការទុកត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៅមន្ទីរ ចៅក្រមស៊ើបសួរ ឬនៅក្នុងបន្ទប់ណាមួយនៃតុលាការដែលមានលក្ខខណ្ឌសន្តិសុខគ្រប់គ្រាន់។ មេធាវី ឬលេខារបស់មេធាវី ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរឱ្យធ្វើការថតចម្លងដោយខ្លួនជាអ្នកចេញសោហ៊ុយលើការចម្លង និងក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។[21]

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួន នៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ជាអាទិ៍ ការពិនិត្យលើសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង ដោយចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីកិច្ចការពិនិត្យនេះទៅព្រះរាជអាជ្ញា ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចធ្វើការចូលរួមដំណើរជាមួយចៅក្រមស៊ើបសួរបាន។ ហើយករណីពិសេស ប្រសិនបើចៅក្រមស៊ើបសួរមានការចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពនៃដែនដីជាតិទាំងមូលបាន។ ប៉ុន្តែក្នុងករណីបែបនេះ ចៅក្រម

---

[19] មាត្រា ១២៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[20] មាត្រា ១២៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[21] មាត្រា ១២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ស៊ើបសួរត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូងនៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ហើយចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីប្រត្តិបត្តិការរបស់ខ្លួននោះផងដែរ។[22]

### ១.១.២.ការស៊ើបសួរជំនួស

#### ១.១.២.១ ដីកាចាត់ឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរអាចឱ្យចៅក្រមផ្សេង មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស។ តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួសនេះដែរ ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។[23] ដីកាចាត់ឱ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសនេះផងដែរ មិនអាចធ្វើឡើងដោយមានលក្ខណៈទូទៅ ទំលំទូលាយពេកនោះទេ គឺត្រូវធ្វើការណែនាំឱ្យបានច្បាស់លាស់។ ជាមួយគ្នានេះដែរ ចៅក្រមស៊ើបសួរត្រូវកំណត់ថិរវេលាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ ដោយត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនោះផ្ទាល់ និងមានបោះត្រាផង។[24] ថ្វីត្បិតតែចៅក្រមស៊ើបសួរបានផ្ទេរសិទ្ធិរបស់ខ្លួនឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ផ្សេងទៀតក៏ពិតមែន ប៉ុន្តែគាត់អាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា។

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានចេញឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនេះមានសិទ្ធិប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ។ ហើយនៅពេលដែរ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់ដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌នោះមានសិទ្ធិប្រើប្រាស់អំណាចតាមប្បញ្ញត្តិដែលបានចែងនៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌនៅក្នុងមាត្រា១៧៨(កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការត្រួតពិនិត្យ រហូតដល់មាត្រា១៨៤(កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌)។ នៅក្នុងពេលអនុវត្តដីកានេះមន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមរូបនោះតែប៉ុណ្ណោះ។

[22] មាត្រា ១៣០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[23] មាត្រា ១៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[24] មាត្រា ១៧៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

### ១.១.២.២ វិធានការនៃការស៊ើបសួរជំនួសរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចដែលមានចែងនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែបប្បញ្ញត្តិនៃកថាខណ្ឌទី២ និងទី៣ នៃមាត្រា៦៨(ការពន្លាតសមត្ថកិច្ចដែនដី)។ ដោយនៅក្នុងកិច្ចនេះ មន្ត្រីនគរបាលត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សីបាន។ មុននឹងឆ្លើយសំណួរ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា និយាយតែការពិត។ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ។ កាលណាការស្តាប់ចម្លើយសាក្សីណាម្នាក់ បានធ្វើឱ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ។ ជាមួយគ្នានេះដែរ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយបកប្រែជូនតុលាការឱ្យបានត្រឹមត្រូវ។

បុគ្គលដែលបានកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែបង្ហាញខ្លួន។ ក្នុងករណីដែលរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជូនចៅក្រមស៊ើបសួរ ដែលអាចចេញបញ្ជាឱ្យចូលខ្លួន ដោយចុះនូវអត្តសញ្ញាណសាក្សី។ បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំឱ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន។[25]

មិនឆ្ងាយពីវិធានការស្តាប់ចម្លើយ នៅក្នុងនីតិវិធីនៃការស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការសួរចម្លើយជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ នេះយោងតាមការកំណត់នៃមាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅដំណាក់កាលនេះ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីចៅក្រមសួរ ទោះបីជាអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែងឬ បើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយសាក្សីនោះផងដែរមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។[26]

[25] មាត្រា ១៧៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[26] មាត្រា ៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ចំពោះពេលវេលាវិញ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចាប់ផ្តើមការឆែកមុនម៉ោង៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចបានឡើយ លើកលែងតែករណីមួយចំនួនដូចជា៖ ករណីបទល្មើសជាក់ស្តែងដូចមានចែងនៅក្នុង មាត្រា៨៦ ករណីដែលចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន ករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។

ការឆែកឆេរនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលក្នុងនោះមានចុះការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនោះ និងអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

ប៉ុន្តែករណីពិសេស មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។ ហើយមន្ត្រីនគរបាលយុត្តិធម៌ក៏អាច ធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌សរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍បាន តែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានាការពារកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយនេះដោយមិនត្រឹមត្រូវ។

ដោយអនុលោមតាមមាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីការបិទស្លាកបោះត្រាលើវត្ថុតាង បានកំណត់ថា មន្ត្រីនគរបាលយុត្តិធម៌អាចចាប់យកវត្ថុតាង ដោយត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរអ្នកមើលរួច មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភណ្ឌនៃវត្ថុដែលចាប់ ដោយកំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១៨៣ ស្តីពីការស្តាប់ទូរស័ព្ទជាអាទិ៍នៅក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួសបានកំណត់ថា កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារតាមទូរសារ ឬសារតាមអិនធើណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឱ្យចៅក្រមស៊ើបសួរ។

### ១.១.៣.ការស៊ើបសួរដោយការស្នើសុំ

បន្ទាប់ពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាមក ចៅក្រមស៊ើបសួរគាត់អាចបំពេញកិច្ចស៊ើបសួរទាំងអស់ដែលគាត់យល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញពីការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក។ ក្រៅពីនេះយើង

ក៏សង្កេតឃើញថា ច្បាប់ក៏អនុញ្ញាតឱ្យបុគ្គលមួយចំនួនមានសិទ្ធិក្នុងការស្នើសុំឱ្យចៅក្រមស៊ើបសួរ បំពេញនូវកិច្ចដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួន។ បុគ្គលទាំងនោះរួមមាន ព្រះរាជអាជ្ញា ជនត្រូវចោទ និងជនដើមបណ្តឹងរដ្ឋប្បវេណី។

### ១.១.៣.១ ការស្នើសុំរបស់ព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រសិនបើចៅក្រមស៊ើបសួរនោះមិនព្រមធ្វើតាម សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនោះ ត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល១៥ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល១៥ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[27]

### ១.១.៣.២ ការស្នើសុំរបស់ជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ដោយពាក្យសុំនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុផងដែរ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា១ខែ បន្ទាប់ពីពេលទទួលបានពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា១ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[28]

### ១.១.៣.៣ ការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឱ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទសួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងចិរវេលា១ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរ

[27] មាត្រា ១៣២ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[28] មាត្រា ១៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

មិនបានសម្រេចក្នុងចិរវេលា១ខែទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[29]

## ផ្នែកទី២៖ កិច្ចការរបស់ចៅក្រមស៊ើបសួរ

### ២.១.ការចុះដល់ទីកន្លែងកើតហេតុ

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួន នៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ជាអាទិ៍ដូចជា ធ្វើការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង ដោយចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការពិនិត្យនេះទៅព្រះរាជអាជ្ញា ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចធ្វើការចូលរួមដំណើរជាមួយចៅក្រមស៊ើបសួរបាន។ ហើយករណីពិសេស ប្រសិនបើចៅក្រមស៊ើបសួរមានការចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពនៃដែនដីជាតិទាំងមូលបាន។ ប៉ុន្តែក្នុងករណីបែបនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូងនៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ហើយចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីប្រតិបត្តិការរបស់ខ្លួននោះផងដែរ។[30]

### ២.២. សួរចម្លើយជនត្រូវចោទ

#### ២.២.១ វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ

ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា១៤៥ បានចែងថា កាលណាជនត្រូវចោទមានមេធាវីអម ដោយចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត៥ថ្ងៃ មុនការសួរចម្លើយ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី។ ជនត្រូវចោទអាចត្រូវបានសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវីនោះបាន។ ហើយនិទ្ទេសស្តីអំពីវត្តមាននេះ ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទផងដែរ។ នៅក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយមិនបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ដោយការបោះបង់នេះ ត្រូវធ្វើការចុះនៅក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។

---

[29] មាត្រា ១៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[30] មាត្រា ១៣០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

នៅក្នុងករណីចំបាច់និងបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនចាំបាច់ កោះហៅមេធាវីបានដែរ។ ដោយភាពបន្ទាន់នេះ ត្រូវតែបណ្ដាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្ដាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់នេះ ត្រូវតែធ្វើការចុះនិទ្ទេសផងដែរនៅក្នុងកំណត់ហេតុ។

### ២.២.២ ការសួរចម្លើយជនត្រូវចោទ

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចធ្វើការលើកឡើងនូវសំណួរទៅលើជនត្រូវចោទនោះបានដែរ ដោយការធ្វើនេះត្រូវតែមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ នៅពេលដែលមានការពិភាក្សាដេញដោល ក្រោមរូបភាពសួរចម្លើយតទល់ជនត្រូវចោទ ហើយនីតិវិធី និងលក្ខខណ្ឌនៃការអនុវត្តអំពីវត្តមានរបស់មេធាវីនៅពេលសួរចម្លើយក៏ត្រូវបានយកមកអនុវត្តផងដែរ។[31]

### ២.២.៣ រយៈពេលនៃការសួរចម្លើយ

កាលណាចិរវេលា៤ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ជន-ត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងចិរវេលា ១ខែ បន្ទាប់ពីមានការសុំនោះទេ នោះជនត្រូវចោទអាចប្ដឹងទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ បន្ទាប់មកកំណត់ហេតុ ត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។[32]

### ២.២.៤ សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្ដីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាចត្រូវគេស្ដាប់ ឬថតបានទេ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្ដីខ្លួនស្ដាប់។ ប៉ុន្តែផ្ទុយទៅវិញ មេធាវីមិនអាចឱ្យលិខិតថតចម្លងពីលិខិតនៃសំណុំរឿង ដល់កូនក្ដីរបស់ខ្លួនបានឡើយ។[33]

## ២.៣. ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

យោងតាមប្បញ្ញតិនៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា១៥០ កំណត់អំពីការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានចែងថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត៥ថ្ងៃមុនការស្ដាប់ចម្លើយ។ នៅក្នុងចិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ ដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានស្ដាប់ចម្លើយតែនៅចំពោះមុខ

[31] មាត្រា ១៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[32] មាត្រា ១៤៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[33] មាត្រា ១៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

មេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមពេលវេលាកំណត់។

## ២.៤. ការចុះឆែកឆេរ និងការចាប់យកវត្ថុតាង

វិធានការអនុវត្តចំពោះការឆែកឆេរនេះ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន។ ច្បាប់បានកំណត់ថា ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី២នាក់ ដែលខ្លួនត្រូវធ្វើការចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ចៅក្រមស៊ើបសួរ មិនអាចធ្វើការចាប់ផ្ដើមឆែកឆេរមុនម៉ោង៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចបានទេ លើកលែងតែះ ក្នុងករណីធ្វើការឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន និងក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

ចំពោះការឆែកឆេរនៅក្នុងការិយាល័យមេធាវីវិញ ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនេះ។ ចៅក្រមស៊ើបសួរត្រូវធ្វើជាកំណត់ហេតុ ស្ដីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២នាក់ ដោយកំណត់ហេតុនេះផងដែរត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ។ វិធានការអនុវត្តចំពោះការឆែកឆេរដែលយើងបានរៀបរាប់ខាងលើនេះ ធ្វើឡើងដោយអនុលោមតាមការកំណត់របស់ក្រមនីតិវិធីព្រហ្មទណ្ឌ។[34]

បន្ទាប់ពីមានការឆែកឆេរហើយ ចៅក្រមស៊ើបសួរអាចយកវត្ថុតាងបាន ដោយការចាប់យកវត្ថុតាងនោះ ចៅក្រមស៊ើបសួរត្រូវតែបិទស្លាកលើវត្ថុតាំងទាំងនោះ។ ដោយបន្ទាប់ពីការបិទស្លាកហើយ ចៅក្រមស៊ើបសួរត្រូវបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់ទីកន្លែង ឬដល់សាក្សី ២នាក់ រួចចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីការចាប់នោះ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្ដីពីការកាប់នេះ ត្រូវមានហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២នាក់ ដោយកំណត់ហេតុនេះ ត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។[35]

ចំពោះការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ យើងឃើញថានៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយនៅឡើយទេ ចៅក្រមស៊ើសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើម

[34] មាត្រា ១៥៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[35] មាត្រា ១៦០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

វិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលពីព្រះរាជអាជ្ញា ដោយដីកាសម្រេចនេះ ត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន ប៉ុន្តែមិនគួរសងទៅឱ្យអ្នកប្តឹងទេ កាលណាវិធានការនេះអាចបង្ករជាឧបសគ្គដល់ការសំដែងឱ្យឃើញការពិត ហើយម្យ៉ាងវិញទៀត វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលកាន់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះ ត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។[36]

### ២.៥. ការស្តាប់ទូរស័ព្ទ

វិធានការនៃការស្តាប់ទូរស័ព្ទ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ យើងឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌយើងបានប្បញ្ញត្តិនៅមាត្រា១៧២ផងដែរ ដោយកំណត់ថា តាមតម្រូវការចាំបាច់ដើម្បីសំដែងឱ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ។ ចៅក្រមស៊ើបសួរអាចធ្វើការបង្គាប់ឱ្យចាប់ និងថតនូវគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬសារតាមអិនធើណែត។ ដោយចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម។

អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ។ នៅក្នុងពេលអនុវត្តបេសកម្ម អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកម្ម ជាអាទិ៍ អំពីការលំបាកជាយថាហេតុ។ កាលណាបេសកម្ម ត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះ ត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលថតបាន។ ការធ្វើឱ្យទៅជាលាយលក្ខណ៍អក្សរនេះ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នូវខ្លឹមសារនៃសំឡេងដែលថតបាន។ សំឡេងដែលថតបាននេះ ត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។ ដោយគ្រប់ពេលវេលា ចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះបាន ដោយការចូលទៅក្នុងទីកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាទីកន្លែងយោធាក៏ដោយ។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសក៏បាន។

[36] មាត្រា ១៦១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

## ផ្នែកទី៣៖ វិធានការនិរន្តរាយ

ដើម្បីធានានៅក្នុងការស៊ើបសួរនេះ ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការធ្វើវិធានការសំខាន់ៗមួយចំនួន ដែលជាកិច្ចមួយរក្សាសុវត្ថិភាពនៅក្នុងការស៊ើបសួរ ដោយយើងអាចនិយាយម្យ៉ាងទៀតបានថា ជាវិធានការទប់ស្កាត់មិនឱ្យមានការអន្តរាយនៅក្នុងការស៊ើបសួរ គេហៅថា វិធានការនិរន្តរាយ។ វិធានការនេះ អនុញ្ញាតឱ្យចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាសំខាន់ៗដើម្បីធ្វើឱ្យដំណើរការនៃការស៊ើបសួរ អាចធ្វើឱ្យបានដោយងាយធានានៃការស៊ើបសួរមិនឱ្យមានឧបសគ្គរំខាន។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។[37]

### ៣.១ ដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាដីកាដែលចៅក្រមស៊ើបសួរបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ដោយដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលដែលមានតម្រុយពិរុទ្ធភាពតែប៉ុណ្ណោះ។[38] នៅក្នុងក្របខណ្ឌនៃការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួននេះ សាមីខ្លួនអាចធ្វើការបង្ហាញខ្លួនដោយសេរី នៅចំពោះមុខចៅក្រមស៊ើបសួរ ដោយគ្មានការទៅនាំខ្លួន ឬចាប់ខ្លួនដោយកម្លាំងសាធារណៈនោះទេ។ នៅក្នុងពេលដែលបង្ហាញខ្លួននោះផងដែរ ចៅក្រមស៊ើសួរធ្វើការសួរយកចម្លើយដែលគាត់ចង់បាន។ ជាទូទៅក្រោយពីការសួរយកចម្លើយ សាមីខ្លួនអាចត្រលប់មកផ្ទះវិញបានដោយសេរី ឬក៏ទទួលបានឃុំខ្លួនជាបណ្ដោះអាសន្ន ប្រសិនបើចៅក្រមស៊ើបសួរមានហេតុផល ដែលសម្រេចថាត្រូវដាក់ជននោះឱ្យត្រូវឃុំខ្លួនបណ្ដោះអាសន្ន។ ដីកាបង្គាប់ឱ្យចូលខ្លួន មិនមានអំណាចបង្ខំទេ មានន័យថា មិនអាចបង្ខំឱ្យគាត់ចូលទេ ដោយសាមីខ្លួនអាចចូលក៏បាន មិនចូលក៏បាន ក៏ប៉ុន្តែការដែលមិនចូលខ្លួន អាចនាំឱ្យចៅក្រមស៊ើបសួរចេញដីកាមួយទៀតគឺ ដីកាបង្គាប់ឱ្យនាំខ្លួន។

ចំពោះនិទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចូលខ្លួននេះ ត្រូវមានដូចជា (១) អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ (២) បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ (៣) ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ (៤) ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកា។ ដីកាបង្គាប់ឱ្យចូលខ្លួននេះ ត្រូវធ្វើការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[39]

[37] មាត្រា ១៨៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[38] មាត្រា ១៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[39] មាត្រា ១៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ហើយនីតិវិធីការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួននេះផងដែរ គឺត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។[40]

## ៣.២ ដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ដោយដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលដែលមានតម្រុយពិរុទ្ធភាពតែប៉ុណ្ណោះ។[41] ហេតុដូចនេះយើងឃើញថា អំណាចនៃដីកាបង្គាប់ឱ្យនាំខ្លួន មានអានុភាពបង្ខំ ដោយតម្រូវឱ្យកម្លាំងសាធារណៈទៅនាំខ្លួនជននោះ មកចំពោះមុខចៅក្រមស៊ើបសួរ ដោយសួរយកព័ត៌មាន និងចម្លើយដែលចៅក្រមស៊ើបសួរចង់បាន។

ចំពោះនិទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យនាំខ្លួននេះ ត្រូវមានដូចជា (១) អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ (២) បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ (៣) ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។ ដីកាបង្គាប់ឱ្យនាំខ្លួននេះ ត្រូវធ្វើការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[42]

ជាគោលការណ៍ នៅពេលចេញដីកានេះហើយ ការអនុវត្តដីកាត្រូវប្រគល់ទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដោយក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួននេះ ត្រូវផ្សព្វផ្សាយជាបន្ទាន់ដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ដើម្បីទទួលអនុវត្តដីកានេះ។ ច្បាប់បានកំណត់អំពីការចុះអនុវត្ត ដោយចែងថា មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦(ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី) ល្ងាចបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការជូនដំណឹងទៅដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកម្មរបស់ខ្លួន ក្នុងដែនកំណត់នៃការអនុវត្តដីកានេះ។

នៅពេលបុគ្គលណាម្នាក់ដែលត្រូវបានចាប់ និងនាំខ្លួនក្នុងក្របខណ្ឌនៃដីកានេះ គេត្រូវតែនាំបុគ្គលនេះទៅបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ ហើយប្រសិនបើការបង្ហាញខ្លួននេះ មិនអាចធ្វើឡើងនៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធគឺត្រូវធ្វើការដោះលែងឱ្យមានសេរីភាពវិញ។[43] ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់

[40] មាត្រា ១៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[41] មាត្រា ១៩០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[42] មាត្រា ១៩១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[43] មាត្រា ១៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួន ឬ ទៅក្នុងពន្ធនាគារ។

ចំពោះការឃុំខ្លួនក្នុងក្របខណ្ឌនៃដីកានេះទៀតសោត ច្បាប់ក៏បានកំណត់អំពីការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដោយបានកំណត់ថា កាលណាបុគ្គលណាម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យឃុំខ្លួននោះ ដោយថិរវេលានៃការឃុំខ្លួននេះត្រូវធ្វើការរាប់បញ្ចូលទៅក្នុងថិរវេលានៃ ការឃុំខ្លួនបណ្តោះអាសន្នផងដែរ ប្រសិនបើមាន។[44]

### ៣.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាដីកាដែលអាចត្រូវចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ លក្ខខណ្ឌដែលចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួននេះបាន លុះត្រាតែៈ (១) បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ហើយ(២) បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ [45] ដីកាបង្គាប់ឱ្យចាប់ខ្លួននេះ គឺជាបញ្ជាៈ

(១) ដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។

(២) ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ។

ដូចនេះដីកាបង្គាប់ឱ្យចាប់ខ្លួននេះ មានន័យថាវាមានអានុភាពតាមតម្លៃច្បាប់ ដែលជាលិខិតឃុំខ្លួនស្របច្បាប់អនុញ្ញាតឱ្យ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឱ្យទទួល និងឃុំខ្លួនតាមអានុភាពនៃដីកានេះ។

មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានថែងមូលហេតុ ក្រោយពីទទួលបានយោបល់ពីព្រះរាជអាជ្ញា ដោយច្បាប់កំណត់ដល់ព្រះរាជអាជ្ញា ធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួននេះ។[46] ហើយចំពោះនិទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចាប់ខ្លួននេះ ត្រូវមានដូចជា (១) អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ (២) បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ (៣) ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកា។ ដីកាបង្គាប់ឱ្យនាំខ្លួននេះ ត្រូវធ្វើការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[47]

---

[44] មាត្រា ១៩៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[45] មាត្រា ១៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[46] មាត្រា ១៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[47] មាត្រា ១៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ចំណែកឯការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួននេះផងដែរ គឺត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដោយក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ តាមគ្រប់មធ្យោបាយ ហើយដើមដីកា ត្រូវប្រគល់ក្នុងរយៈពេលខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តនូវដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង៦ព្រឹក និងក្រោយម៉ោង១៨ល្ងាចបាននោះទេ។ ក្រៅពីនេះផងដែរ ខុសគ្នាពីដីកានាំខ្លួន ដីកាចាប់ខ្លួនអាចត្រូវជាកម្មវត្ថុនៃការផ្សព្វផ្សាយជាសាធារណៈ ជាពិសេសជាលក្ខណៈអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធិភាព។[48]

ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន គឺប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬចុងដីកា ដែលមានបញ្ជាក់ថា ត្រឹមត្រូវចាប់ច្បាប់ដើម។

ទាក់ទងទៅនឹងជោគវាសនា បុគ្គលដែលត្រូវបានចាប់ និងឃុំខ្លួន ច្បាប់បានកំណត់ថា បុគ្គលនោះត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួយចៅក្រមស៊ើបសួរក្នុងរយៈពេលខ្លីបំផុត ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។[49] ប្រសិនបើបុគ្គលដែលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួននោះទេ ព្រះរាជអាជ្ញាត្រូវតែសួរចម្លើយជននោះនៅទីកន្លែងឃុំខ្លួនតែម្តង។ ដោយព្រះរាជអាជ្ញាធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។ ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះ តម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនផ្សេងទៀត ការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ។

ដីកាបង្គាប់ឱ្យចាប់ខ្លួននេះផងដែរ លែងមានអានុភាពទៀតហើយនៅពេលដែលបុគ្គលនោះបានជួបជាមួយចៅក្រមស៊ើបសួរហើយ ដូចនេះប្រសិនបើចង់រក្សាបុគ្គលនោះទៀត គឺត្រូវមានវិធានការដទៃទៀត គឺទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ហើយនិងការចេញដីកាបង្គាប់ឱ្យឃុំខ្លួន។

កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានឃុំខ្លួននោះថិរវេលានៃការឃុំខ្លួននេះ ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន។[50]

---

48 មាត្រា ២០០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

49 មាត្រា ២០១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

50 មាត្រា ២០២ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

### ៣.៤ ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួលឃុំខ្លួន និងឱ្យឃុំខ្លួនជនត្រូវចោទ ហើយចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនទៅបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។[51] មានន័យថា ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នជាមុនសិន ទៅបានចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដោយមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនមុនការសម្រេចឱ្យឃុំខ្លួននោះទេ។ ដូចនេះ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ជាលិខិតឃុំខ្លួនស្របច្បាប់មួយដែលអនុញ្ញាតឱ្យអាជ្ញាធរពន្ធនាគារ ឬមណ្ឌលឃុំឃាំង អាចឃុំខ្លួនបុគ្គលនោះដោយស្របច្បាប់។

ចំពោះនិទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួននេះ ត្រូវមានដូចជា (១) អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ (២) បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ (៣) ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។ ដីកាបង្គាប់ឱ្យឃុំខ្លួននេះ ត្រូវធ្វើការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[52]

ចំពោះការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួននេះផងដែរ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការជូនដំណឹងអំពី ការដោះលែងឱ្យមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន រក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។

## ផ្នែកទី៤៖ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ

ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ជាវិធានការមួយសំខាន់បន្ទាប់ពីវិធានការនៃការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីធានាឱ្យជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។ នៅក្នុងក្របខណ្ឌនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ចៅក្រមស៊ើបសួរជាអ្នកចាត់ចែង ក្នុងការរឹតបន្តឹងលើសេរីភាពរបស់បុគ្គលដែលជាជនត្រូវចោទនោះ។ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការមានគោលដៅសំខាន់ៗចំនួន ៤ធំៗគឺ៖

(១) ធានាឱ្យជនត្រូវចោទ ត្រូវមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។

(២) ការបន្ថយនូវសេរីភាពរបស់ជនត្រូវចោទនូវសកម្មភាពមួយចំនួន ធ្វើយ៉ាងណាឱ្យចៀសវាងការបន្តប្រព្រឹត្តបទល្មើសបន្តទៀត។

[51]មាត្រា ២២០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[52] មាត្រា ២២១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

(៣) ដាក់កំហិតនូវការព្យាបាលផ្នែកសង្គម។

(៤) ដាក់ប្រាក់តម្កល់ ដើម្បីធានាសងការខូចខាតដល់ជនរងគ្រោះដែលអាចកើតមានជាយថាហេតុ។

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទ ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះ ត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។[53] ច្បាប់បានកំណត់ ព្រោះប្រសិនបើយើងពិនិត្យមើលទៅឃើញថា បទល្មើសដែលចោទនោះ មិនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនោះទេ ដូចនេះចៅក្រមស៊ើបសួរមិនអាចយកវិធានការនេះមកដាក់បានទេ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ឱ្យជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

(១)- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

(២)-មិនត្រូវផ្លាស់ប្តូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

(៣)-មិនត្រូវទៅកាន់ទីកន្លែងដែលកំណត់ដោយចៅក្រមស៊ើបសួរ

(៤)-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

(៥)-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

(៦)- ប្រគល់ជូនការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

(៧)- មិនត្រូវបើកបររថយន្ត។

(៨)- មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

(៩)-ដាក់ប្រាក់ធានាដែលចំនួនទឹកប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកលើធនធានរបស់ជនត្រូវចោទ។

(១០)-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

(១១)-ត្រូវប្រគល់ខ្លួនឱ្យមន្ទីរពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

(១២)- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

[53] មាត្រា ២២៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ទាំង១២ចំណុចខាងលើនេះ ជាវិធានការដែលតុលាការអាចដាក់ មួយ ឬច្រើន ក្នុងចំណោមវិធានការទាំង១២នេះ ដូចនេះតុលាការយល់ឃើញថាចំណុចណាមួយក្នុងចំណោម១២ខាងលើនេះ ពាក់ព័ន្ធនឹងអំពើរបស់ជនត្រូវចោទ ដែលមិនត្រូវធ្វើតទៅទៀត។

### ៤.១. ដីកាបង្គាប់ដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមគំនិតផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។[54]

ដីកាសម្រេចដាក់ខ្លួនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការត្រូវ ធ្វើការជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ព្រះរាជអាជ្ញាអាច សុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមសេចក្តីសន្និដ្ឋានរបស់ខ្លួន កាលណាចៅក្រមស៊ើបសួរ ដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា សុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនព្រមសម្រេចតាមការសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ ដោយដីកាសម្រេចនេះត្រូវធ្វើការជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតទៅដល់ព្រះរាជអាជ្ញា ហើយប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃនោះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ៤.២ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ចៅក្រមស៊ើបសួរខ្លួនឯងផ្ទាល់អាចធ្វើការកែប្រែដោយឯកឯង ហើយភាគីដែលជាជនត្រូវចោទ ព្រះរាជអាជ្ញាក៏មានសិទ្ធិប្តឹងសុំធ្វើការកែប្រែដែរ។ នៅពេលចៅក្រមស៊ើបសួរនៅពេលគាត់សម្រេចចេញដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ គាត់បានធ្វើការកំណត់យ៉ាងច្បាស់អំពីកាតព្វកិច្ចដែលជនត្រូវចោទត្រូវធ្វើ ហើយនៅពេលដែលចង់កែប្រែខ្លឹមសារនៃកាតព្វកិច្ច លុបចោលកាតព្វកិច្ច ឬបញ្ចូលកាតព្វកិច្ចថ្មី ដោយច្បាប់បានអនុញ្ញាតឱ្យភាគីទាំងនេះអាចប្តឹងសុំកែប្រែបាន។

#### ៤.២.១ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ

ចំពោះការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឯកឯងរបស់ចៅក្រមស៊ើបសួរ គឺច្បាប់បានអនុញ្ញាតឱ្យ ចៅក្រមស៊ើបសួរអាច កែប្រែខ្លឹមសារនៃកាតព្វកិច្ច លុបចោលកាតព្វកិច្ច ឬបញ្ចូលកាតព្វកិច្ចថ្មីបាន

[54] មាត្រា ២២៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

គ្រប់ពេលវេលា[55] ហើយចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។ ចៅក្រមស៊ើបសួរគាត់ធ្វើការសម្រេចតាមរយៈដីកា ដែលត្រូវធ្វើការជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

### ៤.២.២ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា

ចំណែកឯបណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញាវិញ គឺព្រះរាជអាជ្ញាគាត់អាចធ្វើការប្តឹងសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការនេះ បានគ្រប់ពេលវេលា[56] ដោយចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចសេចក្តីលើការប្តឹងសុំរបស់ព្រះរាជអាជ្ញានេះ ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរលើបណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា គឺត្រូវធ្វើការជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងរយៈពេលមួយដែលខ្លីបំផុត ដោយច្បាប់មិនធ្វើការកំណត់រយៈពេលចំនួនប៉ុន្មានឱ្យប្រាកដនោះឡើយ ត្រឹមតែតម្រូវឱ្យធ្វើការឆ្លើយតបក្នុងរយៈពេលខ្លីបំផុតទៅដល់ព្រះរាជអាជ្ញា។

ករណីដែល ចៅក្រមស៊ើបសួរមិនធ្វើការសម្រេចលើបណ្តឹងនេះ ក្នុងរយៈពេលដែលច្បាប់កំណត់នេះទេ ព្រះរាជអាជ្ញាផ្ទាល់ អាចធ្វើពាក្យសុំទៅសភាស៊ើបសួរ ដែលជានាយឋានានុក្រមរបស់ចៅក្រមស៊ើបសួរ ឱ្យធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ៤.២.៣ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ

ជនត្រូវចោទក៏អាចធ្វើប្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានផងដែរ ដោយជនត្រូវចោទ អាចធ្វើពាក្យសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការនេះ បានគ្រប់ពេលវេលា[57] ចៅក្រមស៊ើបសួរត្រូវធ្វើការបញ្ជូនពាក្យសុំរបស់ជនត្រូវចោទនេះ ភ្លាមទៅព្រះរាជអាជ្ញា ដើម្បីសុំនូវយោបល់ និងជូនសំណុំរឿងនោះទៅព្រះរាជអាជ្ញាផងដែរ ដើម្បីធ្វើការពិនិត្យ។ ក្នុងក្របខណ្ឌនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចយ៉ាងយូរបំផុត ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ដោយធ្វើការរាប់ដោយគិតចាប់ពីថ្ងៃដែលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ហើយកាលណាមានពាក្យសុំលើកលែង ឬឱ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើឡើងជាថ្មីមុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល៥(ប្រាំ)ថ្ងៃនេះ ត្រូវចាប់គិតពីពេលចេញសេចក្តីសម្រេចលើពាក្យសុំពីមុន។ ដោយដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំ ត្រូវតែមាន

[55] មាត្រា ២២៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[56] មាត្រា ២២៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[57] មាត្រា ២២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

សំអាងហេតុ ហើយប្រសិនបើចៅក្រមស៊ើបសួរមិនធ្វើការសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃនេះទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលនឹងធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ៤.៣ ការគេចវេះពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

បន្ទាប់ពីមានការដាក់នូវឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ នូវកាតព្វកិច្ចដែលចៅក្រមស៊ើបសួរនៅពេលគាត់សម្រេចចេញដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ គាត់បានធ្វើការកំណត់យ៉ាងច្បាស់អំពីកាតព្វកិច្ចដែលជនត្រូវចោទត្រូវធ្វើរួចហើយមក ជនត្រូវចោទត្រូវតែគោរព និងអនុវត្តតាមកាតព្វកិច្ចដែលចៅក្រមស៊ើបសួរបានកំណត់មកដែលអាចមាន មួយឬច្រើនតាមកាលៈទេសៈចាំបាច់ដែលចៅក្រមស៊ើបសួរគាត់យល់ឃើញ។ ប្រសិនបើជនត្រូវចោទបានគេចវេះដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ គឺចៅក្រមស៊ើបសួរមិនត្រូវការយកលក្ខខណ្ឌបទល្មើស ឬមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីធ្វើការសម្រេចឃុំខ្លួនត្រូវចោទទៀតនោះទេ ហើយទោះបីជាជនត្រូវចោទធ្លាប់បានឃុំខ្លួនជាបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា ២០៨(ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា២១០(ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍) មាត្រា២១៣(ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ និងមាត្រា២១៤(ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ។[58]

កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមធ្យោបាយការពារកូនក្តីខ្លួន។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទ តាមដីកាដែលមានសំអាងហេតុ ហើយដីកាសម្រេចនេះ ត្រូវធ្វើការជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។

ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ដែលសម្រេចក្រោមក្របខណ្ឌនៃ ការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការនេះ គឺមិនអាចឱ្យលើសពី៤(បួន)ខែចំពោះនីតិជន និងរយៈពេល២(ពីរ)ខែចំពោះអនីតិជន។

[58] មាត្រា ២៣០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

## ៤.៤. ការកោះហៅ និងការជូនដំណឹង

### ៤.៤.១ រយៈពេលរួម

គ្រប់ថិរវេលាដែលយើងបានលើកឡើងមកក្នុងក្របខណ្ឌនៃការស៊ើបសួរនេះ ដើម្បីបំពេញកិច្ច ឬទម្រង់ណាមួយ ត្រូវផុតរលត់នៅថ្ងៃចុងក្រោយវេលាម៉ោង ២៤(ម្ភៃបួន) ហើយរយៈពេលដែលផុតតាមធម្មតានៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ ត្រូវអូសបន្លាយដល់ថ្ងៃទីមួយ ដែលបើកធ្វើការវិញ។ ការកំណត់រយៈពេលរួមបែបនេះឡើង ដើម្បីចៀសវាងវិវាទ ក្នុងការបកស្រាយអំពីរយៈពេលដោយមិនអាចកំណត់បាននូវពេលវេលាច្បាស់លាស់ ហើយមានការខ្វែងគំនិតគ្នាក្នុងពេលអនុវត្ត។[59]

នៅក្នុងករណីដែលមានការទាមទារហត្ថលេខា របស់បុគ្គលណាម្នាក់នៅលើកិច្ចណាមួយនោះ ហត្ថលេខានេះ អាចជំនួសបានដោយស្នាមមេដៃ កាលណាបុគ្គលនោះមិនចេះចុះហត្ថលេខាទេ។

### ៤.៤.២ របៀបនៃការកោះហៅ

ការកោះហៅចំពោះ ជនត្រូវចោទដែលនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ត្រូវបានកោះហៅតាមផ្លូវប្រៃសណីយ៍ តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះការកោះហៅជនត្រូវចោទត្រូវធ្វើឡើងទៅតាមអាសយដ្ឋានចុងក្រោយបង្អស់ ដែលបានប្រកាសអំពីចំណុចនៃការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[60] ចំណែកឯជនដែលត្រូវចោទ ដែលត្រូវបានឃុំខ្លួន ត្រូវធ្វើការកោះហៅតាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[61]

ក្រលេកមកមើលរបៀបនៃការកោះហៅចំពោះមេធាវីវិញ មេធាវីត្រូវកោះហៅតាមផ្លូវប្រៃសណីយ៍ ឬតាមផ្លូវរដ្ឋបាល ហើយក្នុងករណីចំបាច់ ការកោះហៅអាចធ្វើបានតាមគ្រប់មធ្យោបាយ។[62]

ចំពោះនិទ្ទេសនៃការកោះហៅនៅក្នុងសំណុំរឿង គឺវិធីកោះហៅ និងកាលបរិច្ឆេទនៃការកោះហៅ ត្រូវធ្វើការចុះនិទ្ទេសដោយក្រឡាបញ្ជីនៅក្នុងសំណុំរឿង។

### ៤.៤.៣ ការជូនដំណឹង

ការជូនដំណឹងក្នុងក្របខណ្ឌនេះ គឺសំដៅដល់ការជូនដំណឹងអំពីដីកាសម្រេចទៅដល់ភាគីក្នុងសំណុំរឿង ដូចជា៖ ការជូនដំណឹងអំពីដីកាសម្រេចដល់មេធាវី ការជូនដំណឹងអំពីដីកាសម្រេចដល់ព្រះរាជអាជ្ញា និងការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទ។

[59] មាត្រា ២៣១ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[60] មាត្រា ២៣២ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[61] មាត្រា ២៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[62] មាត្រា ២៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ការជូនដំណឹងអំពីដីកាសម្រេចដល់មេធាវី គឺនៅរាល់ពេលដែលដីកាត្រូវជូនដំណឹងដល់ជនត្រូវចោទនោះ ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងដល់មេធាវីផងដែរ ប្រសិនបើជនត្រូវចោទមានមេធាវីអម។[63] នៅរាល់ពេលដែលដីកាត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីផងនោះ ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងដល់មេធាវីផងដែរ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវីអម។

ការជូនដំណឹងអំពីដីកាសម្រេចដល់ព្រះរាជអាជ្ញា ដោយដីការបស់ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដោយផ្ទាល់មាត់ទៅដល់ព្រះរាជអាជ្ញា ហើយក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនេះ នៅរឹមដីកា។[64] ព្រះរាជអាជ្ញាជាអ្នកចុះហត្ថលេខា។ អគ្គព្រះរាជអាជ្ញាត្រូវបានជូនដំណឹងអំពីដីការបស់ចៅក្រមស៊ើបសួរដោយព្រះរាជអាជ្ញាតាមបែបបទដែលអគ្គព្រះរាជអាជ្ញាបានកំណត់។

ការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទគឺ ដីការបស់ចៅក្រមស៊ើបសួរ ដែលត្រូវជូនដំណឹងដល់ជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនតាមរបៀបៈ ដោយផ្ទាល់មាត់ ឬតាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ចំណែកឯ ដីការបស់ចៅក្រមស៊ើបសួរ ដែលត្រូវជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតាមរបៀបដូចជាៈ ដោយផ្ទាល់មាត់ តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។[65]

កាលណាការជូនដំណឹងត្រូវធ្វើឡើងដោយផ្ទាល់មាត់ នោះក្រឡាបញ្ជីចុះនិទ្ទេសអំពីការជូនដំណឹងនៅរឹមដីកា ដោយជនត្រូវចោទឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចុះហត្ថលេខារបស់ខ្លួនផងដែរ។ នៅក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីកា ដោយមានចំណាររបស់អ្នកទទួលទុកជាសម្គាល់។

### ៤.៤.៤ ការប្រគល់ដីកាកោះហៅ ឬដីកាផ្សេងៗទៀត

ការប្រគល់ដីកោះហៅ ឬដីកាផ្សេងៗទៀត គឺគ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាល ឬកងរាជអាវុធហត្ថ ដែលចៅក្រមស៊ើបសួរសុំឱ្យប្រគល់ដីកាកោះហៅ ឬដីកាផ្សេងៗទៀត ត្រូវតែអនុវត្តតាមបញ្ជារបស់ចៅក្រមនេះ។

បុគ្គល អង្គភាព ឬអាជ្ញាធរដែលចៅក្រមស៊ើបសួរចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬដីកាដល់សាមីខ្លួន ដោយមានចំណាររបស់អ្នកទទួលបញ្ជាក់ ថាបានទទួលទុកជាសម្គាល់។ ដីកាដែលមានចំណារទទួលនេះ ត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត។[66]

---

[63] មាត្រា ២៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[64] មាត្រា ២៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[65] មាត្រា ២៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[66] មាត្រា ២៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

# ផ្នែកទី៥៖ ការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដែលផ្ដល់អំណាចធំបំផុតឱ្យចៅក្រមស៊ើបសួរ ហើយក៏ជាវិធានការដែលប៉ះពាល់យ៉ាងខ្លាំងបំផុតដល់សេរីភាពជនត្រូវចោទ ព្រោះដោយហេតុថា ជាគោលការណ៍ជនម្នាក់អាចនឹងត្រូវបានគេឃុំខ្លួន លុះត្រាតែមានសាលក្រមស្ថាពរ ប៉ុន្តែដោយសារតែភាពចាំបាច់ ចៅក្រមស៊ើបសួរគាត់អាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មុនពេលដែលមានការសម្រេចសេចក្ដី។ ដូចនេះ ការឃុំខ្លួនបណ្ដោះអាសន្នគឺ មានភាពចំបាច់មួយដែលត្រូវតែធ្វើក្នុងដំណាក់កាលនៃការស៊ើបសួរ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាជាការចាំបាច់ ជាពិសេសក្នុងពេលដែលចៅក្រមស៊ើបសួរ ស្វែងរកភស្តុតាងផ្សេងៗ ពេលខ្លះតម្រូវឱ្យមានវិធានការបង្ខំ។ ជាគោលការណ៍យើងឃើញថា ជនត្រូវចោទត្រូវតែមានសេរីភាព។[67]

## ៥.១.មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្នគឺជា វិធានការនៅក្នុងករណីពិសេសហើយ ចៅក្រមស៊ើបសួរអាចធ្វើបានតែក្នុងករណីចាំបាច់តែប៉ុណ្ណោះ។ ជាគោលការណ៍គឺសេរីរបស់បុគ្គល ដូចនេះនៅពេលចាំបាច់ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបណ្ដោះអាសន្នដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ហើយតម្រូវតាមលក្ខខណ្ឌដែលបានកំណត់។ ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបានតែចំពោះជនដែល ត្រូវបានចៅក្រមសម្រេចដាក់ឱ្យនៅក្រោមការពិនិត្យ។ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ មានន័យថាចៅក្រមស៊ើបសួរសម្រេច ដាក់ជនណាម្នាក់ឱ្យស្ថិតនៅក្រោមការស៊ើបសួររបស់ខ្លួន ចំពោះបទល្មើសណាមួយដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់អយ្យការ។ ចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។[68]

ការឃុំខ្លួនបណ្ដោះអាសន្នអាចអនុវត្តទៅបានតែ ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ។[69] មានន័យថា គឺសំដៅដល់បទល្មើសធ្ងន់ធ្ងរឡើងទៅ ប្រសិនបើបទល្មើសតូចតាច ដូចជាបទលហុមិនអាចឃុំខ្លួនបណ្ដោះអាសន្នទេ ប្រសិនបើបទល្មើសត្រឹមតែពិន័យជាប្រាក់ក៏មិនអាចនាំឱ្យមានការឃុំខ្លួនបណ្ដោះអាសន្នដែរ ហើយប្រសិនបើបទល្មើសទទួលបានការផ្ដន្ទាទោសក្រោមមួយឆ្នាំ ក៏មិនមែនជាកម្មវត្ថុនៃការឃុំខ្លួនបណ្ដោះអាសន្នផងដែរ។

---

[67] មាត្រា ២០៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[68] មាត្រា ១២៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[69] មាត្រា ២០៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់ដោយចែងនូវវិធានមួយ ដែលកម្រិតអំពីការសម្រេចក្នុងការឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ដោយធ្វើការកម្រិតលើមូលហេតុ។ ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់[70]៖

(១) ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។

(២) ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

(៣) ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

(៤) ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

(៥) ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ ។

(៦) ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

## ៥.២.កំណត់សម្គាល់របស់ជនត្រូវចោទ

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។[71]

ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតាមដីកាដោយមានសំអាងហេតុ ដោយក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា២០៥(មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។

ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន បញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួលឃុំខ្លួន និងងឱ្យឃុំខ្លួនជនត្រូវចោទ ហើយចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនទៅបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ មានន័យថា ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នជាមុនសិន ទើបបានចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដោយមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនមុនការសម្រេចឱ្យឃុំខ្លួននោះទេ។ ដូចនេះ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ជាលិខិតឃុំខ្លួនស្របច្បាប់មួយដែលអនុញ្ញាតឱ្យអាជ្ញាធរពន្ធនាគារ ឬមណ្ឌលឃុំឃាំង អាចឃុំខ្លួនបុគ្គលនោះដោយស្របច្បាប់។ ហើយចំពោះការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួននេះផងដែរ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែ

[70] មាត្រា ២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[71] មាត្រា ២០៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការជូនដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន រក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។

### ៥.៣.ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន មិនមែនធ្វើការឃុំខ្លួនបុគ្គលនោះរហូតនោះទេ គឺមានរយៈពេលកំណត់ច្បាស់លាស់ដើម្បី តម្រូវការលើចាំបាច់សម្រាប់ស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ រយៈពេលកំណត់នេះ ធាតុពិតគឺប្រែប្រួលទៅតាមលក្ខខណ្ឌគតិយុត្តមួយចំនួន ដូចជាលក្ខខណ្ឌបុគ្គលដែលបុគ្គលនោះ ជានីតិជន ឬអនីតិជន និងលក្ខខណ្ឌទាក់ទងទៅនឹងបទល្មើស ដែលត្រូវកំណត់ថា ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍។

#### ៥.៣.១ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះនីតិជន

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋចំពោះនីតិជន គឺមិនអាចលើពី ៦ខែបានទេ។ ប៉ុន្តែនៅពេលផុតរយៈពេលនេះ ចៅក្រមស៊ើបសួរអាចពន្យាពេលការឃុំខ្លួនបាន២(ពីរ)ដងទៀតគត់ ដោយការពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦(ប្រាំមួយ)ខែ ដោយមានដីកាមានសំអាងហេតុត្រឹមត្រូវ។[72] និយាយជារួម នៅក្នុងក្របខណ្ឌនៃការស៊ើបសួរបទឧក្រិដ្ឋធ្ងន់ធ្ងរមួយចំនួន ដែលមានលក្ខណស្មុគស្មាញស៊ាំញ៉ាំមែនទែននោះ វាទាមទារឱ្យការឃុំខ្លួនរយៈពេលវែង រហូតពេលខ្លះ ក្រមនីតិវិធីព្រហ្មទណ្ឌយើងអនុញ្ញាតរហូតទៅដល់ ១៨(ដប់ប្រាំបី)ខែ ព្រោះ ៦ខែបីដង(គិតបញ្ចូលទាំងការអនុញ្ញាតឱ្យពន្យារពេល២ដង)។

ចំពោះបទមជ្ឈិមវិញ ការឃុំខ្លួនបណ្ដោះអាសន្នគឺមានរយៈពេលត្រឹមតែ៤ខែប៉ុណ្ណោះ[73] ដែលជាគោលការណ៍ចៅក្រមស៊ើបសួរមិនអាចសម្រេចឃុំខ្លួនលើរយៈពេលនេះឡើយ។ ប៉ុន្តែ នៅពេលផុតថេរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់ ដោយមិនឱ្យលើស ២(ពីរ)ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើពីអប្បបរមានៃទោសដាក់ពន្ធនាគារដែលច្បាប់បានកំណត់ឡើយ។

ចំពោះបទឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរខ្លាំង សំដៅដល់បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ដោយបទល្មើសទាំងនេះមិនមានអាជ្ញាយុកាលកំណត់ទេ ហើយការឃុំខ្លួនបណ្ដោះអាសន្នក៏មានចរិតលក្ខណៈពិសេសដែរ។ នៅក្នុងក្របខណ្ឌនេះ ការឃុំខ្លួនបណ្ដោះអាសន្នមិន

[72] មាត្រា ២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[73] មាត្រា ២០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

អាចលើសពី១(មួយឆ្នាំ) បានទេចំពោះបទល្មើសនីមួយៗ។[74] ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន១(មួយ)ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ហើយចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យពន្យាការឃុំខ្លួនបណ្ដោះអាសន្ននេះបានតែ២(ពីរ) ដងគត់។

### ៥.៣.២ ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជន

ចំពោះក្របខណ្ឌនៃនៃការអនុវត្តលើអនីតិជនវិញ គឺច្បាប់ធ្វើការបែងចែក រវាងអនីតិជនដែលមានអាយុក្រោម១៤(ដប់បួន)ឆ្នាំ និងអនីតិជនចាប់ពី១៤(ដប់បួន)ឆ្នាំ ទៅដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។

អនីតិជនដែលមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនអាចជាកម្មវត្ថុសម្រាប់ធ្វើការឃុំខ្លួនបណ្ដោះអាសន្នបានឡើយ។[75] មានន័យជារួមថា ចៅក្រមស៊ើបសួរមិនអាចធ្វើការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំបានទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ឱ្យទៅមជ្ឈមណ្ឌលអប់រំថែទាំរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ។

ចំពោះអនីតិជនដែលមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ៖ (១) ការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើពី ៤(បួន)ខែ បានទេ កាលណាជននេះមានអាយុតិចជា ១៦(ដប់ប្រាំមួយ)ឆ្នាំ ,(២) ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦(ប្រាំមួយ)ខែបានទេ កាលណាអនីតិជន មានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។[76]

ចំពោះអនីតិជនដែលមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ៖ (១) ការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើពី ២(ពីរ)ខែ បានទេ កាលណាជននេះមានអាយុតិចជា ១៦(ដប់ប្រាំមួយ)ឆ្នាំ, (២) ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤(បួន)ខែបានទេ កាលណាអនីតិជន មានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។ ហើយបន្ថែមពីលើនេះទៀតផងដែរ ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុច(១) និង(២) ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។[77]

---

[74] មាត្រា ២១០ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[75] មាត្រា ២១២ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[76] មាត្រា ២១៣ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[77] មាត្រា ២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

## ៥.៤.ការដោះលែងឱ្យនៅក្រៅឃុំ

ជាគោលការណ៍ គឺជនត្រូវចោទ ត្រូវតែមានសេរីភាព ប៉ុន្តែករណីពិសេស និងអាចសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នបានតែក្នុងស្ថានភាពចាំបាច់ ស្របតាមលក្ខខណ្ឌនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ទោះបីជាក្រោយពីមានការសម្រេចឃុំខ្លួនបណ្តោះអាសន្នក៏ដោយ គឺអាចមានវិធានការ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាចាំបាច់ គាត់អាចសម្រេចឱ្យនៅក្រៅឃុំបាន។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា។[78] កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងនោះឱ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងនៅព្រះរាជអាជ្ញា។ សេចក្តីសម្រេចឱ្យនៅក្រៅឃុំជាគោលការណ៍មិនមានអនុភាពអនុវត្តភ្លាមទេ គឺត្រូវរង់ចាំរយៈពេលនៃការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា មានន័យថា ជននោះទោះបីមានដីកាសម្រេចឱ្យនៅក្រៅឃុំក៏ដោយ ក៏ជននោះមិនអាចចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួនបានភ្លាមនោះទេ គឺត្រូវរង់ចាំឱ្យព្រះរាជអាជ្ញាពិនិត្យសិន មានន័យថា ទុកសិទ្ធិឱ្យព្រះរាជអាជ្ញាធ្វើការប្តឹងតវ៉ា ក្នុងក្របខណ្ឌនៃការប្តឹងឧទ្ធរណ៍។ ក្នុងរយៈពេលនៃការប្តឹងឧទ្ធរណ៍ ជននោះមិនត្រូវបានអនុញ្ញាតឱ្យនៅក្រៅឃុំនោះទេ លើកលែងតែព្រះរាជអាជ្ញា យល់ព្រមជាលាយលក្ខណ៍អក្សរឱ្យជននោះនៅក្រៅឃុំ បើពុំដូចនេះទេ ជននោះនឹងត្រូវនៅក្នុងឃុំរហូតផុតរយៈពេលប្តឹងឧទ្ធរណ៍ ដែលជាទូទៅមានរយៈពេល ៥(ប្រាំ)ថ្ងៃ។ ប្រសិនជា ព្រះរាជអាជ្ញា សម្រេចធ្វើការប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់ ជននោះត្រូវរក្សាទុកក្នុងការឃុំខ្លួន រហូតដល់សភាស៊ើបសួរដែលមានសមត្ថកិច្ចពិនិត្យ និងដោះស្រាយទៅលើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ននោះ សម្រេចជាមួយបណ្តឹងឧទ្ធរណ៍ថាសម្រេចឱ្យនៅក្រៅឃុំ ឬមិននៅក្រៅឃុំ។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញាឡើយ ដោយចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន។

## ៥.៥.តាមបណ្តឹងរបស់ព្រះរាជអាជ្ញា និងជនត្រូវចោទ

ព្រះរាជអាជ្ញាក៏អាចធ្វើការសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលាផងដែរ។ ដោយការស្នើសុំរបស់ព្រះរាជអាជ្ញានេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ។ ប្រសិនចៅក្រមស៊ើបសួរមិនបានសម្រេចចំពោះការស្នើសុំឱ្យដោះលែងជនត្រូវចោទក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃនោះទេ ព្រះរាជអាជ្ញាអាច

[78] មាត្រា ២១៥ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរតែម្តង។ ហើយចំពោះ ដីកាសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ។[79]

ចំណែកឯជនត្រូវចោទ ក៏ត្រូវបានច្បាប់អនុញ្ញាតឱ្យដាក់ពាក្យសុំឱ្យដោះលែងឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលាផងដែរ។ ចៅក្រមស៊ើបសួរ ត្រូវធ្វើការបញ្ជូនពាក្យសុំដោះលែងឱ្យនៅក្រៅឃុំរបស់ជនត្រូវចោទនេះទៅព្រះរាជអាជ្ញាភ្លាម ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ បន្ទាប់ពីពិនិត្យរួចព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។[80]

ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬនៅសភាស៊ើបសួរក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ ត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំ។ ដោយដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទ អាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ៥.៦.ការជូនដំណឹងអំពីការដោះលែងឱ្យនៅក្រៅឃុំ

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញាលើកលែងតែ ព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញាត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនីតិវិធី។

ក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឱ្យនៅក្រៅឃុំនេះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍។

---

[79] មាត្រា ២១៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[80] មាត្រា ២១៧ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

# ជំពូកទី៣

# ការបិទការស៊ើបសួរ

# ជំពូកទី៣
# ការបិទការស៊ើបសួរ

## ផ្នែកទី១. នីតិវិធីនៃការបិទការស៊ើបសួរ

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរ បិទសំណុំរឿងក្រោមកិច្ចមួយហៅថា ដីកាដំណោះស្រាយ។ ជាទូទៅ ការស៊ើបសួរពុំមានកំណត់រយៈពេលទេ ប៉ុន្តែបើការស៊ើបសួរបានអូសបន្លាយអស់រយៈពេល ១ (មួយ) ឆ្នាំ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការបញ្ចប់កិច្ចស៊ើបសួរបាន ហើយជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីក៏អាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការបិទការស៊ើបសួរបានដែរ ។ ចៅក្រមស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យរបស់ដើមចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលប្តឹងសុំ។ ប្រសិនបើមិនសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញា ឬអ្នកសុំអាចប្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ១.១. ការជូនព័ត៌មានដោយចៅក្រមស៊ើបសួរ

#### ១.១.១ ការជូនដំណឹងដល់គូភាគី

នៅពេលបិទបញ្ចប់ការស៊ើបសួរ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចជូនដំណឹងទៅកាន់គ្រប់ភាគីដែលពាក់ព័ន្ធពោលគឺ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី (ប្រសិនបើមាន) ។ ដោយឡែកការជូនដំណឹងនេះទៀតសោត គ្មានទម្រង់ណាមួយច្បាស់លាស់នោះទេ ។ បន្ទាប់ពីបានជូនដំណឹងក្នុងរយៈពេល ២ (ពីរ) ថ្ងៃ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ការបញ្ជូនសំណុំរឿងគឺជាការចាំបាច់សម្រាប់ឱ្យព្រះរាជអាជ្ញាអាចដាក់ពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ បើគាត់យល់ឃើញថា ការស្រាវជ្រាវផ្សេងទៀតចាំបាច់ដើម្បីបំពេញការស៊ើបសួរដែលធ្វើរួច ។ មិនតែប៉ុណ្ណោះ ការបញ្ជូនសំណុំរឿងក៏ជាការចាំបាច់ណាស់ ដើម្បីអនុញ្ញាតឱ្យព្រះរាជអាជ្ញាផ្តល់យោបល់ទៅលើដំណាក់កាលបន្តនៃសំណុំរឿង តាមរយៈដីកាសន្និដ្ឋានស្ថាពរ ។

បន្ទាប់ពីបានបំពេញកិច្ចស៊ើបសួរដែលសុំដោយគូភាគី ចៅក្រមស៊ើបសួរត្រូវជូនដំណឹងសាជាថ្មីទៅកាន់ភាគីថា គាត់យល់ឃើញថាការស៊ើបសួរត្រូវបិទបញ្ចប់ ។ ការជូនដំណឹងនេះត្រូវមានចិរវេលា ២ (ពីរ) ថ្ងៃ មុនការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ដូចគ្នានេះដែរ បន្ទាប់ពីទទួលសំណុំរឿង ប្រសិនបើព្រះរាជអាជ្ញាសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ហើយការសុំឱ្យមានការស៊ើបសួរបន្ថែមនេះ ត្រូវបានយល់ព្រមដោយចៅក្រមស៊ើបសួរផងដែរ ។ ហេតុនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងពីការបញ្ចប់ការស៊ើបសួរជាថ្មីម្តងទៀត នៅពេលដែលកិច្ចស៊ើបសួរបន្ថែមនោះត្រូវបានធ្វើចប់សព្វគ្រប់ និងបានចុះលេខក្នុងសំណុំរឿង ។

### ១.១.២ ការស្នើសុំបំពេញកិច្ចបន្ថែម

ការស្នើសុំបំពេញកិច្ចបន្ថែម គឺជានីតិវិធីមួយដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា សុំឱ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិត ។ ក្នុងករណីមានការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមណាមួយ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចត្រូវតែស៊ើបសួរតាមការស្នើសុំនោះទេ គឺចៅក្រមស៊ើបសួរអាចបដិសេធស៊ើបសួរ ឬស៊ើបសួរបន្ថែមក៏បាន ប៉ុន្តែត្រូវជូនដំណឹងដល់អ្នកស្នើសុំ ។ ប្រសិនបើគ្មានការជូនដំណឹងអំពីការបដិសេធដល់អ្នកស្នើសុំទេ នោះអ្នកស្នើសុំអាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ប៉ុន្តែការប្តឹងនេះ គឺប្តឹងត្រឹមតែកម្មវត្ថុដែលមានចែងក្នុងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមតែប៉ុណ្ណោះ ។

យើងសង្កេតឃើញថា នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញា អាចស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។ ប្រសិនចៅក្រមស៊ើបសួរមិនព្រមស៊ើបសួរតាមការស្នើសុំទេ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ហើយត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងទៅដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ករណីចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរតាមរយៈពាក្យសុំ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

### ១.២. ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនពត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី (ប្រសិនបើមាន) ។ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃក្រោយមក ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។ ប្រសិនបើព្រះរាជអាជ្ញាគាត់យល់ឃើញថា ចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា) ។ ដោយឡែកក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង ។ ចិរវេលានេះ ត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង ។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញា អាចប្ដឹងឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់ ។[81]

ការបិទការស៊ើបសួរស្ដែងឡើងតាមរយៈដីកាដំណោះស្រាយ ។ ដីកាដំណោះស្រាយនេះ ធ្វើឡើងក្នុងពីរដំណាក់កាល ដោយដំណាក់កាលទីមួយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ (ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី) អំពីឆន្ទៈរបស់ខ្លួនក្នុងការបិទការស៊ើបសួរនៃសំណុំរឿង ។ ដោយឡែកដំណាក់កាលទីពីរ ចៅក្រមស៊ើបសួរអាចចេញដីកាបិទសំណុំរឿងបាន ។ ក្នុងករណីចៅក្រមស៊ើបសួរពុំទាន់ចេញដីកាបិទសំណុំរឿងទេ បានន័យថា ទោះជាបន្ទាប់ពីបានជូនដំណឹងដល់ភាគីឆន្ទៈបិទសំណុំរឿងរួចហើយក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែអាចទទួលបណ្ដឹង និងអាចបន្តការស្រាវជ្រាវរបស់ខ្លួនបានដែរ ។

ដើម្បីជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនត្រូវចោទ នៅពេលផុតចិរវេលា ១ (មួយ) ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី អាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរបាន ។ ក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យសុំ ចៅក្រមស៊ើបសួរត្រូវតែសម្រេច ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ១ (មួយ) ខែទេ ជនត្រូវចោទអាចប្ដឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ជាដល់ចៅក្រមស៊ើបសួរឱ្យសម្រេច ។ ក្នុងករណីពិសេស អំណាចដែលអនុវត្តដោយជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានប្រើប្រាស់ដោយមេធាវី ។[82]

ដោយឡែក តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអាចសុំឱ្យបើកការស៊ើបសួរជាថ្មី ដើម្បីស្រាវជ្រាវបន្ថែម សុំឱ្យលើកលែងការចោទប្រកាន់ ឬសម្រេចបញ្ជូនសំណុំរឿងទៅសាលាជំនុំជម្រះ ។

## ផ្នែកទី២. ប្រភេទនៃដីកាដំណោះស្រាយ

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក ។ យើងសង្កេតឃើញថា បើចេញដីកាដំណោះស្រាយ នោះត្រូវបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន ប៉ុន្តែតាមសេចក្ដីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ តែក្នុងដីកាត្រូវមានបញ្ជាក់អំពីមូលហេតុ ។ បន្ថែមពីនេះទៀត ដីកាដំណោះស្រាយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ ប៉ុន្តែតាមសេចក្ដីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោម

[81] មាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[82] មាត្រា ២៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

ការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ។[83] មិនតែប៉ុណ្ណោះ ដីកាដំណោះស្រាយដែលចូលជាស្ថាពរ មានអានុភាពលុបបំបាត់ចោលពីសំណុំរឿងនូវគ្រប់មោឃភាពទាំងអស់នៃនីតិវិធីមុនប្រសិនបើមាន ។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ ។[84]

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងការចោទប្រកាន់ចំពោះអំពើដទៃទៀត ។ ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន ។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងការចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួរឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។[85]

ក្រោយពីបានទទួលនូវសេចក្តីសន្និដ្ឋានស្ថាពរពីអយ្យការហើយ ចៅក្រមស៊ើបសួរត្រូវធ្វើចំណាត់ការលើសំណុំរឿងដោយធ្វើសេចក្តីសន្និដ្ឋានតាមរយៈដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយនេះ អាចជាដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនទៅជំនុំជម្រះ ។

## ២.១. ដីកាលើកលែងការចោទប្រកាន់

តាមរយៈដីកាលើកលែងការចោទប្រកាន់ ប្រសិនចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុនៃអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុទេ ឬជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ ឬករណីដែលបណ្តឹងអាជ្ញារលត់ ដែលបញ្ជាក់ថាជនត្រូវចោទមានពិរុទ្ធភាពនោះទេ ចៅក្រមស៊ើបសួរសម្រេចចេញដីកាលើកលែងការចោទប្រកាន់ ។[86] ការសម្រេចចេញដីកាលើកលែងការចោទប្រកាន់នេះ ត្រូវមានថែងមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងទៅដល់គ្រប់ភាគីទាំងអស់ ដើម្បីអាចឱ្យភាគីដែលមិនសុខចិត្តនឹងដីកាសម្រេចលើកលែងការចោទប្រកាន់នេះ អាចធ្វើការតវ៉ា ឬដាក់

[83] មាត្រា ២៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[84] មាត្រា ២៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧

[85] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ២០១៣

[86] មាត្រា ២៤៧ថ្មីច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ២០១៣

ពាក្យបណ្តឹងឧទ្ធរណ៍បាន ។ លើសពីនេះ ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់ ក្នុងករណីរលត់បណ្តឹងអាជ្ញា ផុតអាជ្ញាយុកាល ឬមរណភាពនៃចារី ។

ក្នុងករណីដែលមានការលើកលែងការចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថាពាក់ព័ន្ធនឹងបទល្មើស ។ ករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធ (បើមាន) ។ សាលក្រមដែលសម្រេចអំពីការរឹបអូស ត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ។ បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារពត៌មាន ឬមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។[87]

ដីកាលើកលែងការចោទប្រកាន់មិនរលត់បណ្តឹងអាជ្ញាទេ ប្រសិនបើការលើកលែងការចោទប្រកាន់មកពីហេតុផលអវត្តមាននៃបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ឬមកពីការពុំស្គាល់ចារីឡើយ ដូច្នេះ ប្រសិនបើមានបន្ទុកថ្មីលេចឡើង អនុញ្ញាតឱ្យបើកការស៊ើបសួរទៅលើអង្គហេតុនោះជាថ្មីម្តងទៀតបាន ។

### ២.២. ការបើកការស៊ើបសួរលើបន្ទុកថ្មី

ការបើកការស៊ើបសួរលើបន្ទុកថ្មីនេះ គឺនៅក្រោយពេលដែលដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងការចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរ ប្រសិនបើមានលេចឡើងបន្ទុកថ្មី ការបើកការស៊ើបសួរអាចបើកឡើងវិញ តាមការស្នើសុំ ឬការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា ។[88] ចំណែកសំណុំរឿងដែលអាចយកមកបើកការស៊ើបសួរលើបន្ទុកថ្មីបាននោះ លុះត្រាតែដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរមិនបានធ្វើឱ្យរលត់នៃបណ្តឹងអាជ្ញា បានន័យថាប្រសិនបើដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរធ្វើឱ្យរលត់នៃបណ្តឹងអាជ្ញាដោយមូលហេតុដូចជា មរណភាពនៃចារី ផុត

[87] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ២០១៣

[88] មាត្រា ២៥១ ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

អាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ ឬអាជ្ញាអស់ជំនុំ ហេតុនេះព្រះរាជអាជ្ញាមិនអាចស្នើសុំ ឬផ្ដើមគំនិតឱ្យបើកការស៊ើបសួរលើបន្ទុកថ្មីបាននោះទេ ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវដោយយកស្មារតីចិត្តទុកដាក់ ដោយខិតខំឈ្វេងយល់ និងស្វែងរកឯកសារនានាទាំងរដ្ឋធម្មនុញ្ញ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងអត្ថបទច្បាប់ជាច្រើនទៀត ដើម្បីឱ្យលទ្ធផលនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ប្រកបទៅដោយប្រសិទ្ធិភាពកាន់តែខ្ពស់។ ការសរសេរចងក្រងទាក់ទងទៅនឹងដំណាក់កាលស៊ើបសួរ ដែលមានចៅក្រមស៊ើបសួរជាភាគីដ៏សំខាន់ផងនោះ គឺយើងអាចធ្វើការសន្និដ្ឋានបានថា ដំណាក់កាលនៃការស៊ើបសួរ ពិតជាមានលក្ខណស្មុគស្មាញយ៉ាងខ្លាំងក្នុងការអនុវត្ត ដោយត្រូវធ្វើការស្វែងរកការពិត តាមរយៈការស្វែងរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក និងមានភាពប្រទាក់ក្រឡាគ្នាក្នុងទំនាក់ទំនងការងារក្នុងក្របខណ្ឌនៃការស៊ើបសួរ រវាង សភាស៊ើបសួរ ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌។ ក្រៅពីនេះ យើងឃើញថារាល់នីតិវិធីលំអិតៗនានា ក្នុងដំណាក់កាលនេះ តែងតែគោរពនូវគោលការណ៍សំខាន់ៗនៃសិទ្ធិមនុស្ស ដោយធានាមិនមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើង ដោយច្បាប់បានការពារនូវជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋទូទៅ។ ហើយរាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនទៅលើជនណាមួយ នឹងមិនអាចធ្វើឡើងកើតឡើយ លុះត្រាតែអនុវត្តត្រឹមត្រូវតាមច្បាប់កំណត់មក។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវបានហាមមិនឱ្យធ្វើឡើយ និងការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវចិត្តក្តី ផ្លូវកាយក្តី គឺធានាមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពនោះទេ ដោយយើងធ្វើការកំណត់ថា ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សគតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ជាមួយនឹងការផ្តល់សិទ្ធិឱ្យជនគ្រប់រូប មានសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ។

ជាការពិតណាស់ ដូចដែលបានរៀបរាប់នៅក្នុងខ្លឹមសារនៃការស្រាវជ្រាវ យើងឃើញច្បាស់ហើយថា វិធានការដែលអនុវត្តក្នុងក្របខណ្ឌនៃការស៊ើបសួរបានធានានិងការពារនូវកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ជាក់ស្តែងនៅក្នុងវិធានការនៃការបើកការស៊ើបសួរតាមរយៈការប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺតម្រូវឱ្យភាគីដែលជាអ្នកតាំងខ្លួនជាដើមបណ្តឹងរដប្បវេណី ធ្វើការតម្កល់ប្រាក់ ដើម្បីធានាថា នៅពេលដែលបុគ្គលនោះធ្វើបណ្តឹងដោយបំពាន ទៅលើអ្នកដទៃ វាធ្វើឱ្យប៉ះពាល់ទៅដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ ដើម្បីធ្វើជាបន្ទុកមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី មិនឱ្យមានការធ្វើបណ្តឹងតាមតែចិត្តចង់នោះឡើយ។ ម្យ៉ាងវិញទៀត រាល់ការប្រើប្រាស់ពាក្យពេចន៍ដើម្បីសម្រាប់សម្គាល់ឋានៈបុគ្គលដែលត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញា និងរងការស៊ើបសួរ ត្រូវបានគេហៅថា ជនត្រូវចោទ ដោយមិនប្រើប្រាស់ពាក្យពាក្យណាមួយដែលនាំឱ្យប៉ះពាល់កិត្តិយសជននោះ មុខនឹងមានការកាត់ទោសជាស្ថាពរនោះទេ។

ងាកក្រឡេកមកមើលលើឃាត់ខ្លួន ការចាប់ខ្លួន ឬការឃុំខ្លួនជនណាម្នាក់វិញគឺត្រូវតែធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិដែលច្បាប់បានកំណត់មកផងដែរ។ ដូចដែលបានរៀបរាប់នៅក្នុងខ្លឹមសារនៃការស្រាវជ្រាវខាងលើរាល់ការចាប់ខ្លួន ឬឃុំខ្លួន ចៅក្រមស៊ើបសួរ ប្រធានមណ្ឌលឃុំខ្លួន ឬប្រធានពន្ធនាគារ ធ្វើឡើងមកគឺប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងនេះ ហើយចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌនានាដែលក្រមនីតិវិធីព្រហ្មទណ្ឌបានចែងមកជាកំហិត។ បើមិនអនុវត្តឱ្យត្រឹមត្រូវទេគឺ បំពានទៅលើសិទ្ធិរបស់អ្នកដទៃ ហើយក៏អាចនឹងត្រូវប្រឈមនឹងការទទួលទោសទណ្ឌថែមទៀតផង ព្រោះសកម្មភាពទាំងនោះ នឹងនាំឱ្យរកបទល្មើសព្រហ្មទណ្ឌផងដែរ។

ក្នុងចំណោមវិធានណានានារបស់ចៅក្រមស៊ើបសួរ យើងពិតជាចាប់អារម្មណ៍ណាស់នៅក្នុងវិសាលភាពនៃវិធានការនិរន្តរាយ ដែលចាប់បានប្រគល់អំណាចជាច្រើនឱ្យចៅក្រមស៊ើបសួរដើម្បីកុំឱ្យមានការរាំងស្ទះដល់ការស្វែងរកការពិត។ ការចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន សុទ្ធតែមានបំណងចង់ធ្វើការសួរ និងស្តាប់ចម្លើយជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ដោយយោងតាមគោលការណ៍របស់លិខិតូបករអន្តរជាតិនានា ដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ផងដែរនោះ គឺ ការទទួលសារភាពផ្តល់ចម្លើយដែលកើតឡើងដោយការបង្ខិតបង្ខំតាមផ្លូវចិត្តក្តី តាមផ្លូវកាយក្តី គឺច្បាប់កំណត់ថាមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពនោះទេ។

ជាពិសេសទៅទៀតនោះ គឺគោលការណ៍ចម្បងមួយដែលកំណត់ថា ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ គោលការណ៍នេះ បានបញ្ជ្រាបស្មារតីទៅក្នុងវិធានជាច្រើនក្នុងកិច្ចការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដោយមាន សិទ្ធិស្នើសុំឱ្យមានការស៊ើបសួរដោយជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង វត្តមានមេធាវីក្នុងពេលសួរចម្លើយ និងវិធានការផ្សេងៗជាច្រើនទៀត។

ជារួមមក ក្រោយពីបានធ្វើការបកស្រាយខាងលើ យើងឃើញថា ក្រោមនយោបាយកំណែទម្រង់វិស័យយុត្តិធម៌នៅកម្ពុជា ដោយបានបង្កើតនៅក្រមព្រហ្មទណ្ឌថ្មី គឺពិតជាមានលក្ខណៈពេញលេញជាងមុន និងតែងតែបានបញ្ជ្រាបនូវគោលការណ៍សំខាន់ៗចម្បងនានាដែលកំណត់ដោយអង្គការសហប្រជាជាតិ និងទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និងមានការកំណត់នូវនីតិវិធីលំអិតជាច្រើនសម្រាប់ជាប្រយោជន៍ដល់តុលាការក្នុងការអនុវត្តនៅក្នុងដំណើរនៃរឿងក្តីព្រហ្មទណ្ឌដំណាល់កាលចៅក្រមស៊ើបសួរនេះ សម្រាប់ជាមូលដ្ឋានចម្បងដែលចាំបាច់ត្រូវគោរពតាម។

# អនុសាសន៍

ក្រោយពីបានធ្វើការបកស្រាយនូវខ្លឹមសារនៃការស្រាវជ្រាវ និងការធ្វើសេចក្តីសន្និដ្ឋានខាងលើរួចមក យើងអាចសង្កេតឃើញថាដំណើរការនៃរឿងក្តីព្រហ្មទណ្ឌក្នុងក្របខណ្ឌ នៃដំណាក់កាលចៅក្រមស៊ើបសួរពិតជាមានលក្ខណៈល្អពិតប្រាកដមែនដោយបានបង្កើតនូវវិធានជាច្រើនក្នុងដំណាក់កាលនេះ ហើយមានលក្ខណៈប្រទាក់ក្រឡាគ្នា ដោយមានការផ្តល់សិទ្ធិអំណាចទៅលើភាគីក្នុងដំណើរការរឿងក្តី និងបានគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍អន្តរជាតិ ដែលបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទោះជាយ៉ាងណា ក្នុងនីតិវិធីអនុវត្តពេលមានបទល្មើសព្រហ្មទណ្ឌ ក៏នៅតែមានចំណុចមួយចំនួនលេចឡើង ជាចន្លោះប្រហោង ដែលតម្រូវឱ្យមានការកែសម្រួលវិញផងដែរ នៅពេលដែលកំពុងអនុវត្ត និងការកើតឡើងនូវបញ្ហាប្រឈមនាពេលអនាគត។ យើងបានដឹងហើយថាប្រទេសកម្ពុជាយើង មានបទល្មើសជាច្រើនប្រភេទបានកើតឡើង ហើយក្នុងការអនុវត្តគឺតែងតែមានបញ្ហាមួយចំនួនបានលេចឡើង ដែលធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការនេះ ដូចជា ការខ្វះខាតនូវបច្ចេកទេស ខ្វះខាតនូវឧបករណ៍ដើម្បីស្រាវជ្រាវ ការធ្វើកោសល្យវិច័យ បទពិសោធន៍ជាដើម ដែលធ្វើឱ្យមានការចំណាយពេលវេលាច្រើនលើសលុបក្នុងរឿងក្តីនីមួយៗ។

ម្យ៉ាងវិញទៀត យើងសង្កេតឃើញថាវិធានដែលច្បាប់បានកំណត់មកក្នុងដំណាក់កាលស៊ើបសួរនេះ និងការអនុវត្តជាក់ស្តែងហាក់មានភាពមិនស៊ីសង្វាក់គ្នាទាល់តែសោះ ដែលវាអាចមកពីមន្ត្រីវិជ្ជាជីវៈ ដែលពួកគាត់មានទម្លាប់ និងបទពិសោធន៍យ៉ាងក្រាស់ក្រែល ជាមួយច្បាប់ និងនីតិវិធីចាស់ ដែលពួកគាត់ពិបាក និងទម្លាប់ជាមួយច្បាប់ថ្មី ក្រោយមានការផ្លាស់ប្តូរយ៉ាងធំ ដើម្បីបំពេញបន្ថែមនេះ។ ដំណាក់កាលនៃការស៊ើបសួរដូចបានរៀបរាប់ក្នុងខ្លឹមសារនៃអត្ថបទខាងលើ យើងឃើញថាមានវិធានការនិរន្តរាយដែលជាវិធានការមួយដែលតម្រូវឱ្យមានការចាប់ និងដាក់ជនត្រូវចោទក្នុងឃុំ និងត្រួតពិនិត្យតាមផ្លូវតុលាការជាដើម ដែលចៅក្រមស៊ើបសួរជាអ្នកទទួលបន្ទុកទទួលខុសត្រូវក្នុងពេលអនុវត្ត។ ដូច្នេះ បើការអនុវត្តមានភាពមិនប្រក្រតីណាមួយកើតឡើងវានឹងបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ជនត្រូវចោទ។

មួយវិញទៀត យើងខ្ញុំយល់ឃើញថា ដើម្បីបង្ការបទល្មើស និងផ្តល់ភាពយុត្តិធម៌ដល់ជនល្មើស និងជនរងគ្រោះ ដើម្បីស្វែងរកការពិត ក្នុងដំណាលស៊ើបសួរដែលអនុវត្តដោយចៅក្រមស៊ើបសួរ ក៏ដូចជាការធានាការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះ ឱ្យមានប្រសិទ្ធិភាព រដ្ឋគួរតែពង្រឹងកត្តាមួយចំនួនដូចខាងក្រោម៖

- ត្រូវបន្ត និងបង្កើនការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឱ្យបានទូលំទូលាយ ដល់មជ្ឈដ្ឋានទូទៅ និងទូទាំងប្រទេស
- ជ្រើសរើសមន្ត្រីតុលាការដែលមានសមត្ថភាពពិតប្រាកដ និងឱ្យបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែង

- ត្រូវពង្រឹង ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈតាមរយៈការឃ្លាំមើល និងដាក់ពិន័យរាល់ការបំពានក្រមសីលធម៌ទៅលើចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី
- ត្រូវគោរពគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ជាពិសេសត្រូវយកចិត្តទុកដាក់លើ ការគោរពសិទ្ធិទទួលបានការជំនុំជម្រះតាមបែបយុត្តិធម៌
- ចៅក្រមស៊ើបសួរត្រូវតែគោរពឱ្យបានម៉ត់ចត់នូវការហាមឃាត់ទាំងឡាយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ពិសេសគឺរក្សាការសម្ងាត់
- ចៅក្រមស៊ើបសួរត្រូវ គោរពឱ្យបានហ្មត់ចត់ នូវគោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះការបំពេញសកម្មភាពខ្លួនក្នុងដំណាក់កាលរបស់ខ្លួន ព្រោះបើមានតែច្បាប់ ផ្ទុយទៅវិញគ្មានការអនុវត្តឱ្យបានល្អ នោះវានឹងបណ្តាលឱ្យមានភាពអនាធិបតេយ្យ។

ក្រៅពីនេះ គួរពន្លឿននីតិវិធី មានន័យថាចៅក្រមស៊ើបសួរគួរផ្តល់អាទិភាពចំពោះសំណុំរឿងព្រហ្មទណ្ឌទាំងឡាយណាដែលជនត្រូវចោទ ដែលនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នជាពិសេស គឺសំណុំរឿងដែលមានជនត្រូវចោទជាអនីតិជនជាដើម។

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣។
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
- ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣។
- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។
- ច្បាប់ស្ដីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, នស/រកម/០១៧០១៤/០១៦, ១៦ កក្កដា ២០១៤។

## ២. សៀវភៅ និងស្នាដៃនិពន្ធ

- មេរៀននីតិវិធីព្រហ្មទណ្ឌ សហប្រតិបត្តិការបារាំងគំពារទ្រទ្រង់នីតិរដ្ឋ។
- នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និងលោក ខាន់ សុខា។
- សុខ រឿង, មេរៀននីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។
- អាន សូរីដា, ដំណើរការរឿងក្ដីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន, ភ្នំពេញ៖ ឈើវទីម៉ិច គ្រុប។

## ៣. គេហទំព័រ

- http://catalog.libraryrule.com/cgi-bin/koha/opac-detail.pl?biblionumber=17832
- https://web.facebook.com/105934077693845/photos/a.105997847687468/227515722202346/
- https://web.facebook.com/photo?fbid=225999255687326&set=a.111326900487896

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

២. កំណត់ហេតុបង្ហាញខ្លួនដំបូង

៣. កំណត់ហេតុដេញដោលចំពោះមុខ

៤.កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ

៥. ដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន

៦. ដីកាសម្រេចដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យរបស់តុលាការ

៧. ដីកាបង្គាប់ឱ្យចូលខ្លួន

៨. ដីកាបង្គាប់ឱ្យនាំខ្លួន

៩. ដីកាបង្គាប់ឱ្យចាប់ខ្លួន

១០. ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

១១. ដីកាបង្គាប់ឱ្យឃុំខ្លួន

១២. ដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន

១៣. ដីកាបង្គាប់ឱ្យពន្យាពេលឃុំខ្លួន

១៤. ពាក្យសុំដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន

១៥. ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្ន

១៦. ដីកាបង្គាប់ឱ្យដោះលែង

១៧. លិខិតជូនដំណឹងស្តីពីដីកាដំណោះស្រាយ

១៨. ដីកាសន្និដ្ឋានស្ថាពរ

១៩. ដីកាដំណោះស្រាយបញ្ជូនទៅជំនុំជម្រះ

២០. ដីកាសម្រេចរក្សាទុកជនជាប់ចោទក្នុងឃុំរង់ចាំការជំនុំជម្រះ

6/2

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ: 3734 អ.យ.ផ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង : ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ: សំណុំរឿងព្រហ្មទណ្ឌលេខ ៥១៨៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ: ដីកាចាត់តាំងតំណាងអយ្យការលេខ ៥២៦៧ អយក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ: របាយការណ៍សំយោគលេខ១៧៤/២០២០របក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថាមានតម្រុយសន្មតលើ :

ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ,-ទីកន្លែងកំណើតឃុំកុស ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវ៣២ សង្កាត់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្រិតវប្បធម៌បរិញ្ញាបត្រ មុខរបររកស៊ី ឪពុកឈ្មោះ ផៀន សេង "រ" ម្តាយឈ្មោះ នាក់ ឯម "រ" នៅលីវ ជាទីតិជន ទោសពីមុន គ្មាន។ (ឃាត់ខ្លួន)

បានប្រព្រឹត្តអំពើដូចតទៅ៖[1]

កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០២០ ឈ្មោះ , ឈ្មោះ , ឈ្មោះ និងជនសង្ស័យឈ្មោះ ភេទប្រុស អាយុ ២៧ ឆ្នាំ បានព្រមព្រៀងគ្នាបង្កើតក្រុមហ៊ុនមួយឈ្មោះ ដែលមានទន់សរុបជាទឹក ២៤៥០០ (សែសិបពីរម៉ឺនបួនពាន់ប្រាំរយ) ដុល្លាអាមេរិក និងបានប្រគល់ប្រាក់ទាំងអស់នេះឱ្យទៅជនសង្ស័យឈ្មោះ ដើម្បីធ្វើអាជីវកម្មរកផលចំណេញ (Trade Forex)។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ជនសង្ស័យឈ្មោះ បានដកយកប្រាក់ភាគហ៊ុនរួមក្នុងក្រុមហ៊ុន SALEG G ចំនួន១៧៣៦៦០ (ដប់ប្រាំពីរម៉ឺនបីពាន់ប្រាំមួយរយហុកសិប) ដុល្លារអាមេរិក ទៅចាយវាយជាប្រយោជន៍ផ្ទាល់ខ្លួន។ រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ បាននាំខ្លួនជនសង្ស័យមកប្រគល់ជូនសមត្ថកិច្ចការិយាល័យព្រហ្មទណ្ឌ កងរាជអាវុធហត្ថរាជធានីភ្នំពេញតែម្តង។

អំពើខាងលើជាបទល្មើស រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ។

បានឃើញមាត្រា ៤៤ និងមាត្រា១២៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ

---

[1] សេចក្តីសង្ខេបអង្គហេតុ

## ហេតុដូច្នេះសម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើនិង :

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ[2]លើឈ្មោះ សឿង បាន ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ។

☑ ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន:[3] ឈ្មោះ សឿង បាន ភេទប្រុស អាយុ២៧ឆ្នាំ។

*ថ្ងៃសៅរ៍ ៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០*

**តំណាងអយ្យការ**

**ព្រះរាជអាជ្ញារង**

---

[2] ឈ្មោះជនជាប់ចោទ

[3] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងមាត្រា ២០៥

7/6

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

សាលាដំបូងរាជធានីភ្នំពេញ

**បន្ទប់ស៊ើបសួរ "ឆ"**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥១៨៩

ចុះថ្ងៃទី២៤-០៧-២០២០

លេខស៊ើបសួរ.....................

ចុះថ្ងៃទី..................................

(មាត្រា ១៤៣,១៤៤,២៤០ និងមាត្រា២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរម្ភៃ ខែ កក្កដា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោងដប់ និងសាមសិបនាទី

លោក ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោក ជាក្រឡាបញ្ជី ។

បុគ្គលដែលនៅចំពោះមុខយើងបានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម ÷

នាមត្រកូល ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ រកស៊ី ទីកន្លែងកំណើត នៅឃុំកុស ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់ផ្ទះលេខA៣០ ផ្លូវលេខ៣២ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្រិតវប្បធម៌បរិញ្ញាបត្រ ឪពុកឈ្មោះ ជឿន សេង "រ" ម្តាយឈ្មោះ ន នូវលើរ ។

□ ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០" ដប់" ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

□ ជននេះបានប្រាប់ថា ÷ ចេះអាន ចេះសរសេរភាសាខ្មែរ

□ ជននេះបានប្រាប់ថា ÷ មិនចេះអាន និង មិនចេះសរសេរភាសាខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **៣៧៣៤** អ.យ.ដ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ ដែលជាហេតុនាំឲ្យមានការបង្ហាញខ្លួនជននេះនៅចំពោះមុខយើងព្រមទាំងប្រាប់ជននេះឲ្យដឹងពីបទចោទប្រកាន់ចំពោះរឿងរ៉ាវដូចខាងក្រោម[១] ÷

**ពីបទ ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ** ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៤៩៤ និង មាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។

---

(១) រឿងហេតុដែលចោទប្រកាន់ និងបទល្មើស

□យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យ ។

□ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង ។

□ ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម

ដែលយើងបញ្ជាក់ប្រាប់ជននេះអំពីឈ្មោះនៃបទល្មើស ÷

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការសុំឲ្យយើងធ្វើកិច្ចស៊ើបសួរ ឬច្រើន ឬក៏អាចធ្វើពាក្យសុំមោឃភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាននៃមាត្រា២៥៣ ប្តឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា២៦៧ នៅក្នុងពេលនៃដំណើរការនៃការស៊ើបសួរ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

□ យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមានសំណើសុំយើងនឹងចាត់

តាំងមេធាវីមួយរូបជូន ( សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីឲ្យ)

ជនត្រូវចោទបានប្រកាសប្រាប់ថា ÷

□ ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង

□ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

□ ខ្ញុំបដិសេធជំនួយពីមេធាវី

□ យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឲ្យបិទការស៊ើបសួរបាននៅក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

□ យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចឃុំខ្លួនគាត់បណ្ដោះ អាសន្ន ។

យើងបានជូនដំណឹងដល់ជននេះថា ÷ យើងគ្រោងនិងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងរ៉ាវដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់ ។

□ លោក-លោកស្រី________________________________________________មេធាវី(២) នៃជនត្រូវចោទដែលត្រូវបានកោះហៅនៅថ្ងៃទី______ ខែ________ ឆ្នាំ__________ ហើយដើម្បី ឲ្យលោក-លោកស្រីមេធាវីអាចត្រៀមរៀបចំការពារក្ដីខ្លួនបាន ។

□ យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិទទួលបានជំនួយមេធាវីដែលជននេះអាចជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យគេចាត់តាំងមេធាវីណាម្នាក់ឲ្យរូបគាត់ ។

□ យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯង ទេ មេធាវីមួយរូបនឹងត្រូវចាត់ដោយឯកឯង ដោយសារតែជននេះជាអនីតិជន ។

ជននេះបានប្រកាសប្រាប់ថា ÷

□ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

□ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

□ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្ដល់ចម្លើយក៏បាន ឬអាចធ្វើសេចក្ដីប្រកាសផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន ។

ជននេះបានប្រកាសប្រាប់ថា÷ ខ្ញុំអាចឆ្លើយបានដោយខ្លួនឯងដោយពុំចាំបាច់មានមេធាវីការពារក្ដី។

**ជនត្រូវចោទ** **មេធាវី** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-បន្ទប់ស៊ើបសួរ "ឆ"

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២២៧៣

ចុះថ្ងៃទី២៧-០៣-២០២០

-លេខស៊ើបសួរ........................

ចុះថ្ងៃទី.......................................

# កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរម្ភៃ ខែ កក្កដា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោងដប់ និងសាមសិបព្រឹក

លោក ៖ ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោក ៖ ជាក្រឡាបញ្ជី ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៧៣៤ អ.យ.ជ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ បានមកបង្ហាញខ្លួននៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម ៖

នាមត្រកូល ខ្លួន បាន ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ រកស៊ី ទីកន្លែងកំណើតនៅឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់ផ្ទះលេខA៣០ ផ្លូវលេខ៣២ សង្កាត់កាការ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្រិតវប្បធម៌បរិញ្ញាបត្រ ឪពុកឈ្មោះ ចៀន សេង "រ" ម្ដាយឈ្មោះ ជានីតិជន នូវលើរ ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

□ ជននេះប្រកាសប្រាប់ថា៖ ចេះអាន និងចេះសរសេរភាសាខ្មែរ

□ ជននេះប្រកាសប្រាប់ថា៖ មិនចេះអាន និងមិនចេះសរសេរភាសាខ្មែរ

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

---

(១)កំណត់ហេតុត្រូវធ្វើឡើងបន្តពីកំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង (នៅក្នុងថ្ងៃតែមួយ)

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៣៧៣៤ អ.យ.ជ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០

□ដោយមានវត្តមានលោក-លោកស្រី.......................................................................

ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញខ្លួននៅក្នុងបន្ទប់នៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបាន ធ្វើទំនាក់ទំនងដោយសេរីជាមួយនឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខយើង ។

□ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងមានបំណងសម្រេចឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន ។

□ យើងបានប្រាប់ថាជនត្រូវចោទ អាចស្នើសុំពន្យាពេលដើម្បីរៀបចំការពារខ្លួន ។

□ យើងក៏បញ្ជាក់ប្រាប់ជនត្រូវចោទដែរថា យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន នៅថ្ងៃនេះ

□ ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថាជនត្រូវចោទមានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬមេធាវី តាមការចាត់តាំង ។



តំណាងអយ្យការបានបង្ហាញនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម ៖

ស្នើសុំដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទឈ្មោះ ពីបទ

ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

**ជនត្រូវចោទបានបង្ហាញសេចក្ដីសង្ខេបរបស់ខ្លួនដូចខាងក្រោម ៖**

ខ្ញុំឯកភាពឲ្យតុលាការឃុំខ្លួនបណ្ដោះអាសន្ន និងសុំបន្ធូរបន្ថយទោស ។

□ យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ ។

□ យើងបានអញ្ជើញជនត្រូវចោទឲ្យអានឡើងវិញនូវសេចក្ដីប្រកាសទាំងអស់របស់ខ្លួនដែលយើងបាន កត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

□ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចទេ និងបានចុះហត្ថលេខាជាមួយ យើង និងក្រឡាបញ្ជី ។

□ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និង បានចុះហត្ថលេខាជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។

| ជនត្រូវចោទ | មេធាវី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
| --- | --- | --- | --- |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-បន្ទប់ស៊ើបសួរ "ឆ"

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥១៨៩

ចុះថ្ងៃទី២៤-០៧-២០២០

-លេខស៊ើបសួរ..........................

ចុះថ្ងៃទី....................................

# កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
ឆ្នាំពីរម្ភៃ ខែ មីនា ថ្ងៃទីម្ភៃប្រាំបី វេលាម៉ោងបី

លោក ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោក ជាក្រឡាបញ្ជី ។

បានមកបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទ នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខខ្ញុំ ជនដែលមានអត្តសញ្ញាណខាងក្រោម ៖

នាមត្រកូល ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ រកស៊ី ទីកន្លែងកំណើតនៅឃុំកុស ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់ផ្ទះលេខA៣០ ផ្លូវលេខ៣២ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្រិតវប្បធម៌បរិញ្ញាបត្រ ឪពុកឈ្មោះ ជៀន ម្តាយឈ្មោះ ជានីតិជន នូវលីវ ។

▫ ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០"ដប់" ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

▫ ជននេះ ៖ ចេះនិយាយ ▫ចេះអាន ▫ចេះសរសេរអក្សរខ្មែរ

▫ ជននេះ ៖ មិនចេះនិយាយ ▫មិនចេះអាន ▫មិនចេះសរសេរអក្សរខ្មែរ

ពីបទ ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច រាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ

---

(១)ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ
ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ឈ្មោះនេះ យើងបានប្រាប់ដល់ឈ្មោះនេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៧៣៤ អ.យ.ជ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ ដែលជាហេតុនាំឲ្យជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនិង ការឃុំខ្លួនបណ្តោះអាសន្នតាមដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ............ ចុះថ្ងៃទី...................... ខែ.................................. ឆ្នាំ............................................... ។

យើងបាន ក្រោម ៖

ស.ឆ៖ ចម្លើយដែលខ្ញុំបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច និងនៅដំណាក់កាលអយ្យការ ខ្ញុំសូមរក្សាទុកដដែល។

ស.ឆ៖ សាច់ប្រាក់ដែលខ្ញុំទទួលទាំងមុន និង ក្រោយពីពួកគាត់ទាំងអស់ សរុបជាទឹកប្រាក់ចំនួន ៣០០០០០$ (សាមសិបម៉ឺនដុល្លាអាមេរិកត់) (ប្រាក់ទាំងនេះពួកគាត់ខ្ចីពីប្រជាជនដូចមានឯកសារភ្ជាប់មកជាមួយ) ចំពោះទឹកប្រាក់ចំនួន៣០ម៉ឺនដុល្លាទាំងអស់នោះ ពួកគាត់ទាំងបីនាក់ បានឯកភាពដែលមានឈ្មោះដូចជា ឈ្មោះ ដេង ប៊ុនលីន ឈ្មោះ ទូច សុភាព និង ឈ្មោះ ម៉ៅ សុជាតិតា ។ ចំពោះសាច់ប្រាក់ចំនួន២២ម៉ឺនដុល្លាអាមេរិក នៃប្រាក់៣០ម៉ឺនដុល្លានោះ ពួកគាត់បានឯកភាពឲ្យរូបខ្ញុំបាទ យកប្រាក់នេះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

9/02

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ក១"

លេខ៖ 1959 ដ.ព.ស

# ដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

ដោយមានលោក ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ បញ្ញត្តិមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៦០០ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២២

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ........ ចុះថ្ងៃទី.......... ខែ...... ឆ្នាំ.........

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២៣៨ អ.យ.ព ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតឃុំចំការអណ្ដូង ស្រុកចំការលើ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិទូរ៉ៃកណ្ដាល ឃុំព្រែកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ (រស់) ឪពុកឈ្មោះ ប់) ម្ដាយឈ្មោះ ជានិតិជន ប្រវត្តិនៃការផ្ដន្ទាទោសតុលាការ៖ គ្មាន។

ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន ណេសិនណល ឃូ អិល ធីឌី ស្ថិតនៅផ្ទះលេខ៦៣-៦៥ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០២០ និងឆ្នាំ២០២១ បទល្មើសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

## យល់ឃើញថា

-ជនត្រូវចោទឈ្មោះ ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីបទ៖រំលោភលើទំនុកចិត្ត ដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ជាបទល្មើសមជ្ឈិម។

-ជនត្រូវចោទមានលោកមេធាវី ការពារសិទ្ធិឱ្យជនត្រូវចោទ បានដាក់ពាក្យសុំឱ្យសម្រេចមិនឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នដោយសុំឱ្យដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ និងសុំដាក់ប្រាក់ធានាចំនួន ៧០០០$(ប្រាំពីរពាន់ )ដុល្លារអាមេរិក ។

-ជនត្រូវចោទមានទីលំនៅពិតប្រាកដនៅនៅភូមិទូរ៉ៃកណ្ដាល ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

-កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ តាមមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានលក្ខណៈ គ្រប់គ្រាន់ឱ្យជនត្រូវចោទគោរពដើម្បីធានាដល់ការស៊ើបសួរ។

-តាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។

## ហេតុដូច្នេះសម្រេច

មិនឃុំខ្លួនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតឃុំចំការអណ្ដូង ស្រុកចំការលើ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិទូរ៉ៃកណ្ដាល ឃុំព្រែកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ ( ឪពុកឈ្មោះ ) ម្ដាយឈ្មោះ ជាបណ្ដោះអាសន្ននោះទេ ដោយដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ។

012-686243

ថ្ងៃ...............ខែចេត្រ ឆ្នាំខ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២
**ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹង**
ថ្ងៃ...............ខែចេត្រ ឆ្នាំខ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី...... ខែមេសា ឆ្នាំ២០២២
**តំណាងអយ្យការ**

**ក្រឡាបញ្ជី**

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ក១"

លេខ៖ ...1960... ដ.ព.ស

# ដីកាសម្រេច

## ដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

ដោយមានលោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៦០០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ........ ចុះថ្ងៃទី ..... ខែ ....... ឆ្នាំ........

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១២៣៨ អ.យ.ធ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ1959 "ក១"ដ ព ស ចុះថ្ងៃទី.....ខែមេសា ឆ្នាំ២០២២

## សំអាងហេតុ

-ជនត្រូវចោទឈ្មោះ បានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ៖ **រំលោភលើទំនុកចិត្ត** ដែលជាបទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ជនត្រូវចោទឈ្មោះ ត្រូវបានតុលាការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដោយបានសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ ឱ្យអនុវត្តកាតព្វកិច្ចមួយចំនួនតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លើជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិទូរៃកណ្តាល ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ ឪពុកឈ្មោះ ) ម្តាយឈ្មោះ ) ជានិតិជន ប្រវត្តិនៃការផ្តន្ទាទោសតុលាការ៖ គ្មាន។

ដោយឱ្យគោរពកាតព្វកិច្ចដូចខាងក្រោម ៖

ក.មិនត្រូវផ្លាស់ប្តូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពី ចៅក្រមស៊ើបសួរ

ខ.អោយដាក់ប្រាក់ធានាចំនួន៧០០០$(ប្រាំពីរពាន់)ដុល្លារអាមេរិក នៅសាលាដំបូងរាជធានីភ្នំពេញ មិនឱ្យហួសថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ រៀងរាល់ម៉ោងធ្វើការ។

គ.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយ ចៅក្រមស៊ើបសួរ

ឃ.ឱ្យចូលបង្ហាញខ្លួនចំពោះនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំព្រែកពោធិ៍ ជារៀងរាល់ខែនៅថ្ងៃទី០១ នៃខែនីមួយៗ រហូតបញ្ចប់កាស៊ើបសួរ។

២.លោកប្រធាននគរបាលប៉ុស្តិ៍រដ្ឋបាលឃុំព្រែកពោធិ៍ ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ក្នុងករណីដែលជនត្រូវចោទមិនបានបង្ហាញខ្លួនតាមដីកានេះ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
លេខ៖

# ដីកាបង្គាប់ឲ្យចូលខ្លួន

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ របស់ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បង្គាប់មក**

ជនត្រូវចោទឈ្មោះ មានទីលំនៅបច្ចុប្បន្ន

ឲ្យចូលទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង នៅបន្ទប់ ជាន់ទី នៃសាលាដំបូងរាជធានីភ្នំពេញជាកំណត់។

ដើម្បីសាកសួរយកពត៌មានផ្សេងៗដែលជាប់ទាក់ទងនឹងដំណើររឿង៖ ប្រព្រឹត្ត នៅ កាលពីថ្ងៃទី ខែ ឆ្នាំ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា និងមាត្រា នៃក្រមព្រហ្មទណ្ឌ ។

ថ្ងៃ ខែ ឆ្នាំ ព.ស

នៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រមស៊ើបសួរ**

**បញ្ជាក់៖** ករណីរឹងទទឹងមិនចូលមកបង្ហាញខ្លួន
តាមការកំណត់ខាងលើនេះទេ យើងនឹងចេញ
ដីកាបង្គាប់ឲ្យនាំខ្លួន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ
មន្ទីរស៊ើបសួរលេខ:
សំណុំរឿងព្រហ្មទណ្ឌ
លេខ
-លេខ:

# ដីកាបង្គាប់ឲ្យនាំខ្លួន

(មាត្រា១៨៩ និងមាត្រាបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី របស់អយ្យការអមសាលាដំបូងខេត្តកំពង់ធំ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌស៊ើបសួរលេខ: ចុះថ្ងៃទី របស់សាលាដំបូងខេត្តកំពង់ធំ ។

បានឃើញ អង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់លើឈ្មោះ

ទីកន្លែងកំណើតនៅ ទីលំនៅសព្វថ្ងៃនៅ

ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ

មានកូន នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ពីបទ: តាមបញ្ញត្តិមាត្រា ក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ កាលពីថ្ងៃទី ខែ ឆ្នាំ បាន សម្រេចបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ចុះថ្ងៃទី របស់សាលាដំបូងខេត្តកំពង់ធំ ។

ដើម្បីធានាដល់ការស៊ើបសួរឲ្យបានពេញលេញ និងស្វែងរកការពិតក្នុងអង្គហេតុខាងលើ តម្បីសាលាដំបូងខេត្តកំពង់ធំ សម្រេចចេញបញ្ជាឲ្យកម្លាំងសាធារណៈបង្ខំឲ្យនាំសាមីខ្លួនដែលមានឈ្មោះខាងលើ ចូលមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ ។

## សម្រេច

១-បង្គាប់ឲ្យនាំខ្លួនឈ្មោះ ដូចមានសាវតាជាតិខាងលើ មកកាន់សាលាដំបូងខេត្តកំពង់ធំ ។

**ដើម្បី**: សួរចម្លើយពីដំណើររឿងដែលពាក់ព័ន្ធនឹងសំណុំរឿងខាងលើ។

២-បង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ អនុវត្តតាមដីកានេះឲ្យបានសម្រេច ហើយរាយការណ៍មកចៅក្រមស៊ើបសួរគ្រប់ពេលវេលាប្រសិនបើមានហេតុការណ៍កើតឡើងជាយថាហេតុ ក្នុងពេលបំពេញភារកិច្ចនូវផលវិបាកក្នុងការអនុវត្តរបស់កម្មរបស់ខ្លួន ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរជាបន្ទាន់ ។

ថ្ងៃ ខែ ឆ្នាំ ពស

កំពង់ធំ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា១៩៦ និងមាត្រា១៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨/០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានបើកការស៊ើបសួរលើ៖

ជនត្រូវចោទឈ្មោះ មានទីកន្លែងកំណើតនៅ

មានអាសយដ្ឋាន

ពីបទ ប្រព្រឹត្តនៅ

ចំណុច កាលពីថ្ងៃទី ខែ ឆ្នាំ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា

បានឃើញដីកាបញ្ជូនឱ្យឆ្លើយលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## សំអាងហេតុ

១-ចៅក្រមស៊ើសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ ឱ្យជនត្រូវចោទចូលមកបង្ហាញខ្លួនដើម្បីសួរចម្លើយពាក់ព័ន្ធនឹងសំណុំរឿងខាងលើនេះ ប៉ុន្តែនាយរងប៉ុស្តិ៍នគរបាល លោក បានបញ្ជាក់ថាជនត្រូវចោទបានលក់ផ្ទះ និងចាកចេញពុំដឹងទៅរស់នៅទីណាឡើយ ។

២-បទល្មើសចោទប្រកាន់នេះជាបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពីមួយ (១) ឆ្នាំ ទៅបី (៣) ឆ្នាំ ហើយបុគ្គលរូបនេះ បានរត់គេចខ្លួន មិនដឹងជាស្ថិតនៅទីកន្លែងណាទេ ។ ដើម្បីសម្រួលដល់នីតិវិធីស៊ើបសួរឱ្យបានពេញលេញ គប្បីចេញដីកាចាប់ខ្លួនជនត្រូវចោទខាងលើនេះ ។

## ហេតុដូច្នេះសម្រេច

១- ឱ្យចាប់ខ្លួនឈ្មោះ

២-បញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

៣-បញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនេះ និងត្រូវនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ក្នុងរយៈពេលយ៉ាងខ្លី

ថ្ងៃ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រមស៊ើបសួរ**

(ប្រចាំការ)

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានី**
**ភ្នំពេញ**
**បន្ទប់ស៊ើបសួរ ..ណ..**
**សំណុំរឿងព្រហ្មទណ្ឌលេខ**
**៥១៨៩/២៤-០៧-២០២០**
**លេខ...898...ធ.ជ.ព.ស**

## <u>ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញ មាត្រា២០៣ ,២០៤ ,២០៥ និងមាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៧៣៤ អ.យ.ជ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ .................... ចុះថ្ងៃទី....... ខែកក្កដា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានបើកការស៊ើបសួរលើជនត្រូវចោទ៖

-ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌បរិញ្ញាបត្រ មុខរបររកស៊ី មានកន្លែងកំណើតនៅឃុំកុស ស្រុកត្រាំកក់ ខេត្តតាកែវ និងមានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខA៣០ ផ្លូវ៣២ សង្កាត់កាកប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ) ម្តាយឈ្មោះ ) នៅលីវ ជានីតិជន ទោសពីមុន គ្មាន។

-ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ: **រំលោភលើធំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា ជននេះត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោស ដាក់ពន្ធនាគារស្មើ ឬលើសពី ០១ឆ្នាំ ។

-យល់ឃើញថា ការពិភាក្សាដេញដោលចំពោះមុខត្រូវបានធ្វើឡើងតាមនីតិវិធីរួចរាល់ ។

-យល់ឃើញថា កាតព្វកិច្ចទាំងឡាយ នៃការត្រួតពិនិត្យតាមផ្លូវតុលាការមានលក្ខណៈមិនគ្រប់គ្រាន់ ដោយធៀបនឹងគោលដៅដែលមានចែងក្នុងមាត្រា<u>២០៣</u> និងមាត្រា<u>២០៥</u> នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ គឺជាមធ្យោបាយតែមួយគត់ដើម្បី៖

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតឡើងជាថ្មី ។

-ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ។

-ដើម្បីរារាំងកុំឲ្យត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

## <u>ហេតុដូច្នេះសម្រេច</u>

-ឃុំខ្លួនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ បណ្តោះអាសន្ន ។

ថ្ងៃអាទិត្យ ៦កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

យើង...............................ប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១) បានអនុវត្តឃុំខ្លួនឈ្មោះ.........ភេទ
............អាយុ............ឆ្នាំ ជាតិ............ពីបទ......................................................

ប្រព្រឹត្តនៅភូមិ.................សង្កាត់......................ក្រុង................ខេត្ត....................កាលពីថ្ងៃទី.....

ខែ.............ឆ្នាំ................តាមអំណាចដីកានេះកាលពីថ្ងៃទី..........ខែ........ឆ្នាំ............ត្រង់លេខខ្លួន. សំគាល់៖
ឈ្មោះនេះបានឃុំខ្លួនផ្សេងទៀតពីបទ៖...................................................................

កាលពីថ្ងៃទី........ខែ.........ឆ្នាំ.........ត្រង់លេខខ្លួន..............តាមអំណាចដីកាបង្គាប់ឲ្យឃុំខ្លួនលេខ...

ចុះថ្ងៃទីខែ.........ឆ្នាំ...........របស់សាលាដំបូងរាជធានីភ្នំពេញ ។ ( បើគ្មានដាក់ថាគ្មាន )

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..................ឆ្នាំ២០២០

ប្រធានមណ្ឌលអប់រំកែប្រែទី១

(ប្រចាំការ) 12

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានី
ភ្នំពេញ

បន្ទប់ស៊ើបសួរ...
សំណុំរឿងព្រហ្មទណ្ឌលេខ
៥១៩៩/២៤-០៧-២០២០

លេខ: 8765 ធ-ដ.ឃ.ដ

# ដីកាបង្គាប់ឲ្យឃុំខ្លួន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា២០៦,២១៩,២២០,២២១ និងមាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៧៣៤ អ.យ.ដ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ .................... ចុះថ្ងៃទី....... ខែកក្កដា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានបើកការស៊ើបសួរលើជនត្រូវចោទ៖

-ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌បរិញ្ញាបត្រ មុខរបររកស៊ី មានកន្លែងកំណើតនៅឃុំកុស ស្រុកត្រាំកក់ ខេត្តតាកែវ និងមានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខA៣០ ផ្លូវ៣២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្ដាយឈ្មោះ នៅលីវ ជានីតិជន ទោសពីមុន គ្មាន។

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ...5898.........-ទ-ដ.ព.ស ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

## បង្គាប់

១.ឲ្យភ្នាក់ងារមានសមត្ថកិច្ច នៃកងកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ទៅប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១) ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ។

២.ឲ្យប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១) ទទួល និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជា ថ្មីសម្រេចផ្សេងពីនេះ ។

៣.ឲ្យគ្រប់ភ្នាក់ងារ នៃកងកម្លាំងសាធារណៈទាំងអស់សហការណ៍អនុវត្តឲ្យបានល្អ នៅពេល ដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់ ។

ថ្ងៃអាទិត្យ ៦កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

បានទទួល
26.7.2020

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបាត់ដំបង

លេខ ...៣៦២១....គ.ព្រ

# ដីកាសម្រេច
# ពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង។

បានឃើញ បញ្ញត្តិមាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥១៨ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ៥១១ ដស/បស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

បានឃើញ សំណុំរឿងស៊ើបសួរលេខៈ ១០៣៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។

បានឃើញ ដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នលេខៈ ១៨២៤ គ.ព្រ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

បានឃើញដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ១៤៩១ គ.ព្រ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយយល់ឃើញថាៈ ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតភូមិវត្តគរ ឃុំវត្តគរ ស្រុកបាត់ដំបង ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិស្ទើសង្កា ឃុំស្ទើសង្កា ស្រុករតនមណ្ឌល ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) កម្រិតវប្បធម៌ថ្នាក់ទី១១ ទោសពីមុនគ្មាន។

ត្រូវចោទប្រកាន់ពីបទៈ រំលោភសេពសន្ថវៈ (មានស្ថានទម្ងន់ទោសដោយជនល្មើសច្រើនរូប និង ដោយគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់) ប្រព្រឹត្តនៅចំណុចភូមិស្ដៅ ឃុំស្ដៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ។

យល់ឃើញថាៈ ការពន្យារពេលឃុំខ្លួនជនត្រូវចោទមានក្នុងមូលហេតុដូចខាងក្រោម៖

☐ ១-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី។

☐ ២-ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរារាំងចៀសវាងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

☐ ៣-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

☑ ៤-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការតាមនីតិវិធី។

☐ ៥-ដើម្បីការពារសុវត្ថិភាពជនត្រូវចោទ ។

☐ ៦-ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។

32
3

**ហេតុដូច្នេះ សម្រេច**

ពន្យារពេលឃុំខ្លួនបុគ្គលដែលមានឈ្មោះខាងលើនេះ ដើម្បីជានាដល់កិច្ចស៊ើបសួរតាមនីតិវិធីនៃច្បាប់។

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅបាត់ដំបង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

Tolaw

បានទទួលដំណឹងហើយ

លេខ......៣៥៤......................

ថ្ងៃទី..៣០...ខែឧសភា...ឆ្នាំ២០២២

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង

លេខ ...៦២២.....ត.ព្រ

## ដីកាបង្គាប់ឱ្យពន្យារពេលឃុំខ្លួន

យើង [illegible] ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

បានឃើញ បញ្ញត្តិមាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៥១៨ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ៥១១ ជស/បស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

បានឃើញ សំណុំរឿងស៊ើបសួរលេខៈ ១០៣៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។

បានឃើញ ដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្នលេខៈ ១៨២៤ ត.ព្រ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១៤៩១ ត.ព្រ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

បានឃើញ ដីកាសម្រេចពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្នលេខៈ..៦២១........ត.ព្រ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

**បង្គាប់ឱ្យពន្យារពេលឃុំខ្លួនជនត្រូវចោទឈ្មោះ** [illegible] ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតភូមិវត្តគរ ឃុំវត្តគរ ស្រុកបាត់ដំបង ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិរស្មីសង្ហា ឃុំរស្មីសង្ហា ស្រុករតនមណ្ឌល ខេត្តបាត់ ដំបង នៅលីវ ឪពុកឈ្មោះ [illegible] (រ) ម្ដាយឈ្មោះ [illegible] (រ) កម្រិតវប្បធម៌ថ្នាក់ទី១១ ទោសពីមុនគ្មាន។

ត្រូវចោទប្រកាន់ពីបទៈ **រំលោភសេពសន្ថវៈ** (មានស្ថានទម្ងន់ទោសដោយជនល្មើសច្រើនរូប និងដោយគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់) ប្រព្រឹត្តនៅចំណុចភូមិស្ពោ ឃុំស្ពោ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ។

បង្គាប់មកប្រធានពន្ធនាគារខេត្តបាត់ដំបង ពន្យារពេលឃុំខ្លួនឈ្មោះនេះជាបណ្ដោះអាសន្នឱ្យបានសម្រេចតាមដីកាបង្គាប់នេះ ។

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅបាត់ដំបង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល
លេខ......១៣៣០៨៧......
ថ្ងៃទី១៣ ខែ១១ ឆ្នាំ២០២០
ម៉ោង......០៤ និង ៥១ នាទី
ក្រឡាបញ្ជី

**ពាក្យសុំដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន**

ខ្ញុំបាទឈ្មោះ ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ ទីលំនៅមុនចាប់ខ្លួនស្នាក់នៅ ផ្ទះលេខ A៣០ ផ្លូវ ៣២ សង្កាត់ កាកាបទី២ ខណ្ឌ ពោធិ៍សែនជ័យ រាជធានី ភ្នំពេញ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ ។

**ជូនទៅក្រុមបន្ទប់ ពិនិត្យ និងចាត់ការ**

**<u>សូមគោរពចូលមក</u>**

**លោកចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ**

*<u>សូមទានជ្រាប!</u>*

**កម្មវត្ថុ:** សំណើសុំដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន ។

**យោង:** សំណុំរឿងព្រហ្មទណ្ឌលេខ៥១៨៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា: កាលពីថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២០ ខ្ញុំបាទត្រូវបាន លោកចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការឃុំខ្លួនបណ្ដោះអាសន្ន នៅមណ្ឌលអប់រំកែប្រែទី១ នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ដែលមានដីកាឃុំខ្លួនលេខ: ៨៧៦៥"ទ"ងឃង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២០ ជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** នៅពេលនេះខ្ញុំបាទស្នើសុំលោកចៅក្រមមេត្តាអនុញ្ញាតឲ្យខ្ញុំបាទបាននៅក្រៅឃុំបណ្ដោះអាសន្ន ពីព្រោះខ្ញុំបាទត្រូវរកស៊ីចិញ្ចឹមគ្រួសារដែលមានឪពុកម្ដាយចាស់ជរាមិនមានអ្នកមើលថែ។

ខ្ញុំបាទសូមសន្យាថានឹងចូលខ្លួន តាមការកំណត់គ្រប់ដំណាក់កាល នៃនីតិវិធីរបស់តុលាការ នៅពេលមានដីកាកោះហៅមិនបង្កការលំបាកឡើយ មិនផ្លាស់ប្ដូរទីលំនៅ ដោយគ្មានការអនុញ្ញាត ។

អាស្រ័យដូចបានជម្រាបជូនតាមកម្មវត្ថុខាងលើ សូម **លោកចៅក្រម** មេត្តាពិនិត្យ និងអនុញ្ញាតដោះលែងខ្ញុំបាទបាននៅក្រៅឃុំបណ្ដោះអាសន្នដោយក្ដីអនុគ្រោះ ។

សូម **លោកចៅក្រម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃ សុក្រ ១៣រោច ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២០

**ស្នាមមេដៃស្ដាំ**

លេខ:...០១៥.....ម១

**<u>បញ្ជាក់</u>**

ស្នាមមេដៃខាងស្ដាំនេះពិតជារបស់

ជនត្រូវចោទឈ្មោះ សឿង បាន ដែលកំពុងឃុំខ្លួន

នៅមណ្ឌលអប់រំកែប្រែទី១ ពិតប្រាកដមែន។

ថ្ងៃ សុក្រ ១៣រោច ខែ កត្តិក ឆ្នាំ ជូត ទោស័កព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២០

**ប្រធានមណ្ឌល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៥១៨៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ ៣៦២៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរអក្សរ -ធ- ជាន់ទី៤**
លេខ 8681 -ទ-ជ.ព.ស

## ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន

យើង ជាចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី

-បានឃើញ របាយការណ៍សំយោគលេខ ១៧៤/២០ រ.ប.ក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៧៣៤ អ.យ.ជ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងអយ្យការ( ) នៃអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបើកការស៊ើបសួរលើឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៨៧៦៥ -ទ-ជ.យ.ជ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០**នៅមណ្ឌលអប់រំកែប្រែទី១ (ម១)។

-បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយលេខ ៥៩៣ -ទ-ព្រ.ទ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០។ តំណាងអយ្យការ( ) បានផ្តល់យោបល់លើដីកាបញ្ជូនឲ្យឆ្លើយលើពាក្យសុំនៅក្រៅឃុំជាបណ្តោះអាសន្នថា **៦អគតា៣**។

### ១-ប្រវត្តិរូបជនត្រូវចោទ

-ឈ្មោះ **ភេទប្រុស អាយុ២៧ឆ្នាំ** ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ បរិញ្ញាបត្រ មុខរបររកស៊ី មានកន្លែងកំណើតនៅឃុំកុស ស្រុកត្រាំកក់ ខេត្តតាកែវ និងមានទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខA៣០ ផ្លូវ៣២ សង្កាត់កាកប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ) ម្តាយឈ្មោះ ) នៅលីវ ជានីតិជន ទោសពីមុន គ្មាន។

### ២-យល់ឃើញថា

**១.១-យល់ឃើញថា:** ជនត្រូវចោទឈ្មោះ បានឆ្លើយថា នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០២០ ឈ្មោះ ឈ្មោះ , ឈ្មោះ និងខ្លួន បានសហការគ្នាបង្កើតទម្រង់កិច្ចសន្យាកម្ចីប្រាក់ពីអតិថិជន ដោយសន្យាជាមួយនឹងអតិថិជនផ្តល់អត្រាការប្រាក់ ៥ភាគរយក្នុងមួយខែ ដោយក្នុងរយៈពេល៦ខែ ដកដើមជូនត្រឡប់វិញ និងបញ្ចប់កិច្ចសន្យា។ ចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុនេះ មានលក្ខណៈ ជាកិច្ចសន្យាក្រុមហ៊ុន និងការខ្ចីបរិភោគ (យោងកិច្ចសន្យាក្រុមហ៊ុន និងខ្ចីបរិភោគ ឯកសារ ១/៧២) និងមានការអនុវត្តកាតព្វកិច្ច ឬពុំមានចេតនាទុច្ចរិតឡើយ រាល់ការអនុវត្តការងារភាគហ៊ុន គឺមានការឯកភាពពីម្ចាស់ភាគហ៊ុនក្នុងការអនុវត្តប្រតិបត្តិការ និងមានឯកសារទូទាត់ច្បាស់លាស់។

**១.២-យល់ឃើញថា:** ដោយសារតែជនត្រូវចោទឈ្មោះ បានចូលមកផ្តល់ចម្លើយនៅចំពោះមុខតុលាការ គាត់មានអាស័យដ្ឋាន និងការងារពិតប្រាកដ មានក្រុមគ្រួសារដែលស្ថិតក្នុងបន្ទុករបស់គាត់។ ការឃុំខ្លួនជនត្រូវចោទអាចនាំឲ្យប៉ះពាល់ ដល់ប្រតិបត្តិការក្រុមហ៊ុន និងអតិថិជនដែលត្រូវចូលមកដោះស្រាយជាមួយភាគីម្ចាស់ភាគហ៊ុន និងការខ្ចីប្រាក់របស់ភាគីកូនបំណុល ម្យ៉ាងវិញទៀត ជនត្រូវចោទសន្យាថាខ្លួនមានលទ្ធភាពដោះស្រាយលើបំណុល ដែលមានក្នុងក្រុមហ៊ុន និងខ្លួនបានចូលដោះស្រាយ ជាមួយអតិថិជនផង និងសុំមកបង្ហាញខ្លួនតាមការត្រួតពិនិត្យរបស់តុលាការជានិច្ច។ ដូច្នេះតុលាការសម្រេចមិនឃុំខ្លួនគាត់ ដើម្បីឲ្យគាត់មានសេរីភាព ស្របតាមមាត្រា២០៣ ដោយមិនមានតម្រុយចាំបាច់ ដែលបានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឡើយ ។

១.៣-យល់ឃើញថាៈ បទល្មើសខាងលើជាបទមជ្ឈិម ការដែលឲ្យជនត្រូវចោទនៅក្រៅឃុំ មិនបង្កលក្ខណៈស្មុគស្មាញដល់តុលាការនោះទេ ដូច្នេះចៅក្រមស៊ើបសួរ សម្រេចមិនឃុំខ្លួនជនត្រូវចោទ ។

១.៤-យល់ឃើញថាៈ ក្រោយការស៊ើបសួរ តុលាការពិនិត្យឃើញថាមានទាក់ទិន នឹងអញ្ញត្តិជនមួយចំនួនក្នុងអង្គហេតុដែលត្រូវស៊ើបសួរបន្ថែមទៀត រីឯការឃុំខ្លួនជនត្រូវចោទជិតផុតកំណត់ ការស៊ើបសួរមានការជឿនលឿន រីឯការឃុំខ្លួនជាបណ្ដោះអាសន្នដើម្បីស៊ើបសួរ ពុំមានអានុភាពចាំបាច់ គប្បីដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយហេតុថា ជនត្រូវចោទមានមុខរបរ និងរស់នៅស្ថានច្បាស់លាស់។

## ៣-ហេតុដូច្នេះសម្រេច

៣.១-អនុញ្ញាតឲ្យឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ បាននៅក្រៅឃុំបណ្ដោះអាសន្ន។

៣.២-បញ្ជាដល់លោកប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១) ឲ្យដោះលែងឈ្មោះ [redacted] ដូចមានក្នុងដីកាដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨៧៦៥ "ទ"ជ.យ.ជ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០។

ថ្ងៃ...៣...១...............ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២០

ចៅក្រមស៊ើបសួរ

ក្រឡាបញ្ជី

បានទទួលដំណឹងរួចហើយ

ថ្ងៃ..................ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២០

តំណាងអយ្យការ

[redacted]

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៥១៨៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

សំណុំរឿងស៊ើបសួរលេខ ៣៦២៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរអក្សរ "ឆ" ជាន់ទី៤**

លេខ 12518 "ទ"ដ.ឃ.ជ

## ដីកាបង្គាប់ឲ្យដោះលែង

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សំយោគលេខ១៧៤/២០រ.ប.ក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **៣៧៣៤ អ.ឃ.ជ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០** របស់តំណាងអយ្យការ( នៃអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបើកការស៊ើបសួរលើឈ្មោះ **ភេទប្រុស អាយុ២៧ឆ្នាំ** ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយលេខ ៥៩៣ "ទ"ព្រ.ទ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០។ តំណាងអយ្យការ បានផ្ដល់យោបល់លើដីកាបញ្ជូនឲ្យឆ្លើយលើពាក្យសុំនៅក្រៅឃុំជាបណ្ដោះអាសន្នថា **ចៅក្រមសម្រេចតាមច្បាប់។**

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៨៧៦៥ "ទ"ដ.ឃ.ជ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០** លើជនត្រូវចោទឈ្មោះ **ភេទប្រុស អាយុ២៧ឆ្នាំ** ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌បរិញ្ញាបត្រ មុខរបរកេស៊ី មានកន្លែងកំណើតនៅឃុំកុស ស្រុកត្រាំកក់ ខេត្តតាកែវ និងមានទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខA៣០ ផ្លូវ៣២ សង្កាត់កាកប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្ដាយឈ្មោះ ) នៅលីវ ជានីតិជនទោសពីមុន គ្មាន។

-បានឃើញ ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ ...8681."ទ"ដ.ព.ស ចុះថ្ងៃទី.១៨. ខែវិច្ឆិកា ឆ្នាំ២០២០ ចៅក្រមស៊ើបសួរ ដោយមានការឯកភាពពីតំណាងអយ្យការ ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

### ហេតុដូច្នេះសម្រេច

១-បញ្ជាដល់លោកប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១) ឲ្យដោះលែងជនត្រូវចោទឈ្មោះ ; ប្រសិនបើឈ្មោះនេះ មិនត្រូវឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ ។

២-សូមគោរពជូនដំណឹងដល់លោកប្រធានមណ្ឌលអប់រំកែប្រែទី១ (ម១) ថា ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨៧៦៥ "ទ"ដ.ឃ.ជ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០ អស់សុពលភាពអនុវត្ត ។

ថ្ងៃ....[illegible]..........ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី.១៨. ខែវិច្ឆិកា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ

ថ្ងៃ.......[illegible].....ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២០

**តំណាងអយ្យការ**

២៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបាត់ដំបង**

លេខ:...១០៨៩.....ត.ព្រ/២១

# លិខិតជូនដំណឹង

(ស្តីពីដីកាដំណោះស្រាយ)

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤៧៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនត្រូវចោទឈ្មោះ [redacted], ភេទប្រុស អាយុ២៩ឆ្នាំ។(ឃុំខ្លួន)

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិចុងពរ ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ជម្រាបមក**

ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិព្រៃខ្លា ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ អាសយដ្ឋានបច្ចុប្បន្នភូមិព្រៃស្វាយ ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី០៧ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤៧៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនរឿងទៅជំនុំជម្រះហើយ។

អាស្រ័យហេតុនេះសូមឈ្មោះ [redacted] ជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១៤រោចខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅបាត់ដំបង ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

[redacted]

**បានទទួល**

ថ្ងៃទី..........ខែ.......ឆ្នាំ២០២២

**ជនត្រូវចោទ**

62
២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តកំពង់ចាម
សំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៩៥
ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១
លេខៈ...៤៨៣...អ.យ.យ/២១

# ដីកាសន្និដ្ឋានស្ថាពរ

**យើង** **តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម**

- បានឃើញ មាត្រា ២៤៦ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ៤៧៣ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ចាម។
- បានឃើញ សំណុំរឿងស៊ើបសួរលេខៈ៤៨៦ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។
- បានឃើញ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខៈ៥០៦៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានគម្រុយសន្មតលើៈ

១ -គោត្តនាម-នាម : ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ។
ទីកន្លែងកំណើត : ភូមិទួលសុភ័រ ឃុំទួលសុភី ស្រុកអូរាំងឪ ខេត្តកំពង់ចាម។
ទីលំនៅបច្ចុប្បន្ន : ភូមិបែកអន្លូង ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។
មុខរបរ : កម្មករ។
ឪពុកឈ្មោះ : (ស) និងម្តាយឈ្មោះ (រ)។
ស្ថានភាពគ្រួសារ : រៀបការប្រពន្ធឈ្មោះ (រ) មានកូន០២នាក់។
ប្រវត្តិនៃការផ្តន្ទាទោស : គ្មាន។

២ -គោត្តនាម-នាម : ហៅ ភេទប្រុស អាយុ២៨ឆ្នាំ សញ្ជាតិខ្មែរ។
ទីកន្លែងកំណើត : ភូមិផ្អាវ ឃុំផ្អាវ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។
ទីលំនៅបច្ចុប្បន្ន : ភូមិបែកអន្លូង ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។
មុខរបរ : កម្មករ។
ឪពុកឈ្មោះ : (រ) និងម្តាយឈ្មោះ (ស)។
ស្ថានភាពគ្រួសារ : នៅលីវ។
ប្រវត្តិនៃការផ្តន្ទាទោស : គ្មាន។

ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ ពីបទ "លួច" ប្រព្រឹត្តនៅចំណុចចំការកៅស៊ូសមាគមន៍ខ្មែរវេស្លាម ស្ថិតនៅភូមិគីឡូល ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

### បានប្រព្រឹត្តអំពើដូចតទៅៈ

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៧ និង៤០នាទី មានជនសង្ស័យឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជិះម៉ូតូម៉ាក សង់ការ៉េ(ម៉ូតូចាស់) និងជនសង្ស័យឈ្មោះ ហៅ ភេទប្រុស អាយុ២៨ឆ្នាំ ជិះម៉ូតូម៉ាក គប់ (ម៉ូតូចាស់) បានចូលទៅលួចជ័រកៅស៊ូសមាគមន៍ខ្មែរវេស្លាម នៅចំណុចភូមិគីឡូល ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់

ខេត្តកំពង់ចាម ប្រដាប់ទៅដោយអាវុធកែច្នៃ០១ដើម និងដាវ០១ដើម។ ក្រោយពីធ្វើសកម្មភាពរួច ជនសង្ស័យទាំងពីរនាក់ខាងលើត្រូវបានម្ចាស់សមាគមន៍ចំការកៅស៊ូខ្មែរឥស្លាម ធ្វើការឃាត់ខ្លួនបាន និងបញ្ជូនខ្លួនជនសង្ស័យខាងលើមកកាន់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីកសាងជាសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកំពង់ចាម ចាត់ការទៅតាមនីតិវិធីច្បាប់។

## ឃើញថា៖

-បានឃើញ របាយការណ៍សំយោគ លេខ ៥២៥ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១ របស់មន្ត្រីនគរបាលយុត្តិធម៌។ (យោងឯកសារលេខ ៣២)។

-បានឃើញ កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៤២)។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នឈ្មោះ លេខ ១២១៣ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៤៤)។

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនឈ្មោះ លេខ ១២១៤ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៤៥)។

-បានឃើញ កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៤៧)។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នឈ្មោះ លេខ ១២១៥ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៤៩)។

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនឈ្មោះ លេខ ១២១៦ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៥០)។

-បានឃើញ កំណត់ហេតុសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៥៣)។

-បានឃើញ កំណត់ហេតុសួរចម្លើយសាក្សីឈ្មោះ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៥៥)។

-បានឃើញ កំណត់ហេតុសួរចម្លើយសាក្សីឈ្មោះ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៥៧)។

-បានឃើញ កំណត់ហេតុសួរចម្លើយសាក្សីឈ្មោះ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៥៩)។

-បានឃើញ លិខិតជូនដំណឹងស្តីពីការបិទការស៊ើបសួរលេខៈ ៥០៦៨ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៦០)។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខៈ ៥០៦៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម។ (យោងឯកសារលេខ ៦១)។

## យល់ឃើញថា

១.ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា៖ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង៥ល្ងាច ខ្លួនកំពុងដើរល្បាតមើលការខុសត្រូវនៅក្នុងចំការកៅស៊ូ ខ្លួនក៏បានឃើញមនុស្សប្រុស២នាក់ (ស្គាល់មុខតែមិនស្គាល់ឈ្មោះ) កំពុងតែជក់ថ្នាំញៀន ខ្លួនចង់ដឹងថាគេធ្វើអ្វីបន្តទៀតក៏នៅចាំលួចមើល ហើយចំងាយដែលខ្លួនលួចមើលមនុស្សប្រុស២នាក់នោះក៏ចាប់ផ្តើមបកជ័របង្អកក្នុងចាននោះ ឃើញដូចនេះខ្ញុំក៏បានស្រែកហៅឈ្មោះ ឈ្មោះ និងកម្មករដទៃទៀតឲ្យទៅជួយចាប់ខ្លួនមនុស្សប្រុស២នាក់នោះ។ នៅពេលពួកខ្លួនដេញចាប់ពួកវាក្នុងចំការកៅស៊ូរបស់ខ្លួន ឃើញមានកាំភ្លើងខ្យល់១ដើម ថ្នាំញៀនចំនួន០២កញ្ចប់ និងដាវចំនួន០១ដើមនៅនឹងខ្លួនពួកវា ដោយម្នាក់កាន់ដាវ ហើយម្នាក់ទៀតកាន់កាំភ្លើង ចំណែកឯកៅស៊ូដែលពួកវាលួចនោះ គឺវាបានក្រវែងចោល

នៅក្នុងចំការកៅស៊ូនោះបាត់ហើយ លុះក្រោយមកខ្លួនក៏បានទូរស័ព្ទហៅសមត្ថកិច្ចមកធ្វើការឃាត់ខ្លួនមនុស្សប្រុស២នាក់នោះតែម្តង។

២.ផ្អែកតាមចម្លើយរបស់ជនត្រូវចោទឈ្មោះ      នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា៖ ខ្លួន និងឈ្មោះ   បាននាំគ្នាទៅចំការកៅស៊ូតាម គោលបំណងទៅដក់ថ្នាំញៀន មិនទាន់បានដក់ផង ក៏ស្រាប់តែម្ចាស់ចំការគេមកទាន់ ប្តឹងសមត្ថកិច្ចឲ្យចាប់ខ្លួនតែម្តង។

៣.ផ្អែកតាមចម្លើយរបស់ជនត្រូវចោទឈ្មោះ      នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា៖ នៅថ្ងៃមិនចាំ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង៣រសៀល ខ្លួន និងឈ្មោះ      បាននាំគ្នាជិះម៉ូតូម្នាក់មួយគ្រឿង ដោយពួកខ្លួនមានដាវចំនួន០១ដើម អាវុធកែច្នៃ(ប្រើហ្គាស)ចំនួន០១ដើម ធ្វើពីទុយោជ័រ បាញ់ប៉ាដាងកង់ ជារបស់ឈ្មោះ      ចំណែកខ្លួនមានថង់ផ្លាសស្ទិចពណ៌ខ្មៅ ចំនួន០១ គោលបំណងទៅបាញ់សត្វ តែពួកខ្លួនបាញ់សត្វមិនបាន ក៏នាំគ្នាជិះម៉ូតូចូលមកក្នុងឡូត៍កៅស៊ូ ស្ថិតនៅភូមិតីឡូល ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ដើម្បីមកកាត់ក្រោយចាន់ទី តែពេលនោះពួកខ្លួនមិនបានកាត់ក្រោយចាន់ទីទេ ពួកខ្លួនក៏នាំគ្នាដក់ថ្នាំញៀនសិន។ ពួកខ្លួនរៀបចំដក់ថ្នាំញៀន ស្រាប់តែពួកខ្លួនឃើញម្ចាស់គេមកដល់ ពួកខ្លួនក៏មិនបានដក់ថ្នាំញៀនឡើយ រៀបចំមកផ្ទះវិញ ក៏ត្រូវបានពួកគេចាប់ខ្លួនតែម្តង។ ខ្លួនមិនមានបំណងទៅលួចជ័រកៅស៊ូគេឡើយ។

៤.ផ្អែកតាមចម្លើយរបស់សាក្សីឈ្មោះ      ឈ្មោះ      ឈ្មោះ      នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោងប្រហែល៥ល្ងាច ពួកខ្លួននៅចំការចំណុចភូមិតីឡូល ដោយសារតែកន្លងមកចេះមានជនមិនស្គាល់មុខតែងតែចូលចំការ ហើយបាត់ជ័រចានកៅស៊ូរហូត ទើបពួកខ្លួនបាននាំគ្នារងចាំពួនស្ទាក់ ដោយមានគ្នា០៤នាក់ ចាំមើលពួកលួចជ័រនោះ នៅចំនុច(ចំការសមាគមន៍រូម) ស្រាប់តែពេលនោះឈ្មោះ      បានឃើញជនសង្ស័យ០២នាក់ (មិនស្គាល់អត្តសញ្ញាណទាំង០២នាក់នោះទេ) ជិះម៉ូតូ០២គ្រឿងចូលទៅក្នុងចំការ ហើយគាត់បានគេប្រាប់គ្នាថា មានមនុស្សជិះចូលមកហើយ តែកុំធ្វើព្រោះមិនដឹងមនុស្សល្អ ឬអាក្រក់ទេ ពួកខ្លួនក៏បានពួនមើល ហើយឃើញពួកវាអង្គុយទល់មុខគ្នាមិនដឹងធ្វើអ្វីនោះទេ។ មួយស្របក់ក្រោយមកពួកវានាំគ្នាដើរបេកជ័រចាន ហើយពួកខ្លួនបាននាំគ្នាប្រាប់គន្នាថា ពួកវាលួចជ័រហើយ ពួកវាដឹងខ្លួនផ្អើល ហើយព្យាយាមជិះម៉ូតូរត់គេច តែត្រូវពួកខ្លួនដេញតាមចាប់ពួកវាទាំង២នាក់តែម្តង និងក៏បានប្រគាយប្រគល់។

៥.ផ្អែកតាមសំអាងហេតុចំណុចទី(១) ចំណុចទី(២) ចំណុចទី(៣) និងចំណុចទី(៤)ខាងលើ អំពើរបស់ជនត្រូវចោទឈ្មោះ      និងឈ្មោះ      ហៅ      ពិតជាបានធ្វើសកម្មភាព លួចជ័រកៅស៊ូ ដែលជារបស់សមាគមន៍ខ្មែរឥស្លាម គឺបំពេញធាតុផ្សំនៃបទល្មើស លួច បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៦.ជនត្រូវចោទឈ្មោះ      និងឈ្មោះ      ហៅ      ជានីតិជន មានសតិសម្បជញ្ញៈ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវ ចំពោះអំពើរបស់ខ្លួនបាន។ អំពើប្រព្រឹត្តរបស់ជនត្រូវចោទបានធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិអ្នកដទៃ និងប៉ះពាល់សណ្តាប់ធ្នាប់របៀបរៀបរយនៅក្នុងសង្គម ដែលគប្បីទទួលរងទណ្ឌកម្មព្រហ្មទណ្ឌ។

៧.មានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដែលអាចឱ្យតុលាការជំនុំជម្រះលើតម្រុយពិរុទ្ធភាពរបស់ជនត្រូវចោទឈ្មោះ      និងឈ្មោះ      ហៅ      គឺជាបទ “លួច” ប្រព្រឹត្តនៅចំណុចចំការកៅស៊ូសមាគមន៍ខ្មែរឥស្លាម ស្ថិតនៅភូមិតីឡូល ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

ប្តឹងសុំឱ្យចៅក្រមស៊ើបសួរ សម្រេចបញ្ជូនទៅជំនុំជម្រះនូវ៖

១.ឈ្មោះ      (សាវតារជាតិខាងលើ)

២.ឈ្មោះ      ហៅ      (សាវតារជាតិខាងលើ)

ពីបទ "លួច" ប្រព្រឹត្តនៅចំណុចចំការកៅស៊ូសមាគមន៍ខ្មែរឥស្លាម ស្ថិតនៅភូមិគីឡូ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

ថ្ងៃ..[illegible]...៦កើត........ ខែភទ្របទ......... ឆ្នាំឆ្លូវ ត្រីស័ក ឆ្នាំ២៥៦៥

កំពង់ចាម ថ្ងៃទី[illegible]...ខែ[illegible].. ឆ្នាំ២០២១

**តំណាងអយ្យការ**

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ១៦០០
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ១២២០
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២
ចៅក្រមស៊ើបសួរ អក្សរ "ធ" ជាន់ទី៤
លេខ ...3513..... "ទ" ដ.ផ

## ដីកាដំណោះស្រាយបញ្ជូនទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** មាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-**បានឃើញ** ពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **១២៣៨ អ.យ.ធ** ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខ **២៩៤ "ទ" ព្រ.ទ** ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ **១៩៦០ "ក១" ដ.ព.ស** ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ**ដីកាសន្និដ្ឋានស្ថាពរលេខ **២៦២៥ អ.យ.ធ** ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការ ) បានសម្រេចចោទប្រកាន់ឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ (ក្រៅឃុំ) **ទៅជំនុំជម្រះ** ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន ស៊ីកី &អេ ត្រេឌីងអ៊ិនធើណេសិនណល យូ អិលធីឌី ស្ថិតនៅផ្ទះលេខ៦៣-៦៤ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ និងឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

### អង្គហេតុមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០២០ និងឆ្នាំ២០២១ នៅចំណុចក្រុមហ៊ុន ស៊ីកី &អេ ត្រេឌីងអ៊ិនធើណេសិនណល យូ អិលធីឌី ស្ថិតនៅផ្ទះលេខ៦៣-៦៤ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជនត្រូវចោទឈ្មោះ ឈិត ឈុយ ភេទ ប្រុស អាយុ ៣២ឆ្នាំ បានចូលបំរើការងារនៅក្នុងក្រុមហ៊ុនតាំងពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ មានតួនាទីជាបុគ្គលិកផ្នែកលក់របស់ក្រុមហ៊ុន មានភារៈកិច្ចលក់ផលិតផល និប្រមូលប្រាក់ពីអតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុន ដោយទទួលបានប្រាក់ខែ ២៨០ ដុល្លារអាមេរិក ក្នុងមួយខែ ។ រហូតដល់ចុងឆ្នាំ២០២១ ទើបក្រុមហ៊ុនបានធ្វើការត្រួតពិនិត្យបញ្ជីចំណូលចំណាយប្រចាំឆ្នាំ២០២០ និងឆ្នាំ២០២១ របស់ក្រុមហ៊ុន បានរកឃើញថា ឈ្មោះ ឈិត ឈុយ កិបកេងប្រាក់របស់ក្រុមហ៊ុនសរុបចំនួន ១៦.៥០៩(មួយម៉ឺនប្រាំមួយពាន់ប្រាំរយប្រាំបួន)ដុល្លារអាមេរិក ហើយបានគេខ្លួនបាត់ពុំអាចទំនាក់ទំនងបាន ។

### សំអាងហេតុ

១-យោងតាមពាក្យបណ្តឹង និងចម្លើយរបស់ជនត្រូវចោទ ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់បានថា ៖ ឈ្មោះ ពិតជាបានប្រព្រឹត្តសកម្មភាព **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន ស៊ីកី &អេ ត្រេឌីងអ៊ិនធើណេសិនណល យូ អិលធីឌី ស្ថិតនៅផ្ទះលេខ៦៣-៦៤ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ និងឆ្នាំ២០២១ ប្រាកដមែន។

-អំពើប្រព្រឹត្តិរបស់ជនត្រូវចោទឈ្មោះ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាម មាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ក្នុងពេលប្រព្រឹត្តិបទល្មើសជនត្រូវចោទឈ្មោះ ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងនូវអំពើដែលខ្លួនបានប្រព្រឹត្ត និងត្រូវទទួលខុសត្រូវតាមកំណត់ច្បាប់ ។ មានភាពស៊ីសង្វាក់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ ដែលបញ្ជាក់បានថាជនត្រូវចោទឈ្មោះ អាចមានតម្រុយពិរុទ្ធភាពពីបទ **រំលោភលើទំនុកចិត្ត** ។

២-ដីកាសន្និដ្ឋានស្ថាពរលេខ **២៦២៥** អ.យ.ធ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការ ( ) មានហេតុផលសមស្របតាមច្បាប់ គប្បីសម្រេចតាមការប្តឹងសុំ ។

៣-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ(ក្រៅឃុំ) **ទៅជំនុំជម្រះ** ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងខែមីនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២០ តាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៤-តាមមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាដំណោះស្រាយបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ តែដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីសម្រេចក្នុងដីកាដំណោះស្រាយឱ្យជនត្រូវចោទគោរពកាតព្វកិច្ចក្នុងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ **១៩៦០ "ក១" ជ.ព.ស** ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ រហូតដល់ពេលចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

## ហេតុដូច្នេះសម្រេច

១-បញ្ជូនជនត្រូវចោទ៖

-ឈ្មោះ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិដងផ្ចិត ឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ ទីលំនៅបច្ចុប្បន្នស្នាក់នៅ ភូមិត្រពាំងអម្ពិល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ខាំ ឃិន ម្តាយឈ្មោះ ពិន សួស (ក្រៅឃុំ) ។

ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន ស៊ីភី &អេ គ្រេឌីងអ៊ិនធើណេសិនណល ឃូ អិលធីឌី ស្ថិតនៅផ្ទះលេខ៦៣-៦៤ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ និងឆ្នាំ២០២១ តាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-សំណុំរឿងព្រហ្មទណ្ឌលេខ **១៦០០** ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅសាលាដំបូងរាជធានីភ្នំពេញ **ដើម្បីកំណត់ពេលជំនុំជម្រះ** ។

២-រក្សាទុកជនត្រូវចោទឈ្មោះ ភេទ ប្រុស អាយុ ៣២ឆ្នាំ ឱ្យគោរពកាតព្វកិច្ចក្នុងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ **១៩៦០ "ក១" ជ.ព.ស** ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២ រហូតដល់ពេលចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

**បានទទួលដំណឹង** ថ្ងៃសុក្រ ២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ថ្ងៃ.សុ.ក្រ.២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

រាជធានីភ្នំពេញ ថ្ងៃទី.១៥.. ខែកក្កដា ឆ្នាំ២០២២ **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**តំណាងអយ្យការ**

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង
លេខ ៤៧៩ ត.ព្រ

## ដីកាសម្រេចរក្សាទុកជនជាប់ចោទ
## ក្នុងឃុំរង់ចាំការជំនុំជម្រះ

យើង , ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ **១៦៥៥** ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ **១១២១** ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលេខ ៦១៤ ដស.បស ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ។

-បានឃើញដីកាបង្គាប់ឱ្យឃុំលេខ **១៦២៤** ត.ព្រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ។

-បានឃើញដីកាដំណោះស្រាយលេខ ៣៥៤ ដ.ជ.រ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ។

ក្រោយពីបានពិនិត្យ និងពិចារណាចប់សព្វគ្រប់អស់ហើយ

យល់ឃើញថា មានភាពចាំបាច់រក្សាទុកជនជាប់ចោទឈ្មោះ ញឹក ប៊ុនរ័ត្ន ភេទប្រុស អាយុ ៤២ឆ្នាំ ដែលបានឃុំខ្លួនតាមដីកាសម្រេចលេខ **១៦២៤** ត.ព្រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ឱ្យនៅជាប់ឃុំរហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការដើម្បីៈ

-ធានារក្សាជនត្រូវចោទទុកជូនសាលាដំបូងខេត្តបាត់ដំបងចាត់ការតាមនីតិវិធីច្បាប់។

-ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើសដោយ យោងតាមមូលហេតុខាងលើ។

## ហេតុដូច្នេះសម្រេច

១.រក្សាជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ ឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

**២**.បង្គាប់ឲ្យលោកប្រធានមន្ទីរឃុំឃាំង នៃពន្ធនាគារខេត្តបាត់ដំបង រក្សាជនត្រូវចោទដែលមានសាវតារជាតិដូចខាងលើឲ្យនៅក្នុងឃុំបណ្តោះអាសន្នបន្តទៅទៀតរងចាំការជំនុំជម្រះតាមច្បាប់។

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
បាត់ដំបង, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**